ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងផែនការ

# ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេឌ័រក្រសួងផែនការ (ផយបយផក) បច្ចុប្បន្នកម្ម ២០០៩-២០១៣

ខែធ្នូ ឆ្នាំ២០១០

ឧបត្ថម្ភបោះពុម្ពដោយៈ

UNFPA

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងផែនការ

# ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្រសួងផែនការ (ផយបយផក) បច្ចុប្បន្នកម្ម ២០០៩-២០១៣

ខែធ្នូ ឆ្នាំ២០១០

ឧបត្ថម្ភបោះពុម្ពដោយៈ

UNFPA

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីបង្ហាញនូវ *ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្រសួងផែនការ (ផយបយផក) បច្ចុប្បន្នកម្ម ២០០៩-២០១៣* របស់ក្រសួងផែនការ ។ ឯកសារនេះគឺជាសមិទ្ធផលដ៏សំខាន់នៃកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារយេនឌ័រក្រសួងផែនការ ដើម្បីឆ្លើយតបទៅនឹង គោលនយោបាយជាយុទ្ធសាស្ត្រ និងសកម្មភាព ជាអាទិភាព ដែលមានចែងនៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រង់កថាខ័ណ្ឌលេខ ៥៥៦ និងដែលបានលើកឡើងនៅក្នុង *ផែនការយុទ្ធសាស្ត្រ-ក្រសួងផែនការ (ផយផក) បច្ចុប្បន្នកម្ម ២០០៩-២០១៣* (ចំណុចដៅទី១៨) ។ ឯកសារនេះគឺជាឧបករណ៍ដ៏សំខាន់របស់ក្រសួងផែនការក្នុងការជំរុញ និងលើកកំពស់សមភាពយេនឌ័រ ។ កម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសក្នុងតំបន់ដែលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការកាត់បន្ថយភាពក្រីក្រ និងព្យាយាមដោះស្រាយនូវបញ្ហានៃការអភិវឌ្ឍមនុស្ស ជាពិសេស សមភាពយេនឌ័រ និងសិទ្ធិរបស់ស្ត្រីនៅក្នុងគ្រប់ទិដ្ឋភាពអភិវឌ្ឍន៍ ។

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ១៩៩៦-២០០០ ឆ្នាំ២០០១-២០០៥ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥ របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ២០០៣-២០១៥ គោលនយោបាយជាតិប្រជាជន យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១និងដំណាក់កាលទី២ ផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ បានលើកឡើងនិងដោះស្រាយបញ្ហាយេនឌ័រ និងផ្តល់នូវយុទ្ធសាស្ត្រនិងសកម្មភាពអនុវត្តនានា ដើម្បីលើកកម្ពស់សមធម៌យេនឌ័រ និងកាត់បន្ថយគម្លាតយេនឌ័រ ។ ការរៀបចំនិងអនុវត្ត *ផយបយផក បច្ចុប្បន្នកម្ម ២០០៩-២០១៣* របស់ក្រសួងផែនការ គឺជាចំណុចដៅមួយនៃ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ។ ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រនិងសកម្មភាពអាទិភាពដែលមានចែងនៅក្នុងបណ្តាឯកសារខាងលើ ក្រសួងផែនការបានសហការជិតស្និទ្ធជាមួយក្រសួងកិច្ចការនារី និងមានការចូលរួមពិគ្រោះយោបល់ទូលំទូលាយពីអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ដើម្បីរៀបចំ *ផយបយផក បច្ចុប្បន្នកម្ម ២០០៩-២០១៣* ។

*ផយបយផក បច្ចុប្បន្នកម្ម ២០០៩-២០១៣* គឺជាក្របខ័ណ្ឌ ការងារដ៏មានសារៈសំខាន់មួយសម្រាប់ក្រសួងផែនការ និងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ក្នុងប្រព័ន្ធផែនការ ។ ផែនការនេះ មិនត្រឹមតែឆ្លុះបញ្ចាំង ពីការទទួលស្គាល់អំពីភាពចាំបាច់ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរសេដ្ឋកិច្ច-សង្គមកិច្ច និងនយោបាយជាវិជ្ជមានចំពោះស្ត្រីប៉ុណ្ណោះទេ តែបានផ្តល់បន្ថែមនូវការណែនាំ និងទិសដៅ ដើម្បីសម្រេចឱ្យបាននូវសមភាពយេនឌ័រ ក្នុងប្រព័ន្ធផែនការទាំងមូល ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះការចូលរួម និងផ្តល់អនុសាសន៍ ពីអ្នកមានចំណែកពាក់ព័ន្ធដើម្បីរៀបចំ *ផយបយផក បច្ចុប្បន្នកម្ម ២០០៩-២០១៣* ។ ជាពិសេស ក្រសួងផែនការសូមថ្លែងអំណរគុណចំពោះមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន ដែលបានរួមវិភាគទានយ៉ាងច្រើន រួមទាំងការផ្តល់ជំនួយបច្ចេកទេស ទីប្រឹក្សា និងថវិកា ដល់ក្រុមការងារយេនឌ័រ ក្រសួងផែនការ សម្រាប់រៀបចំឯកសារនេះ ។

ទីបញ្ចប់ខ្ញុំសូមថ្លែងអំណរគុណចំពោះ ក្រុមការងារយេនឌ័រក្រសួងផែនការដែលដឹកនាំដោយ ឯកឧត្តម **ទ្វី និហាត** ដែលបានផ្តល់យោបល់ណែនាំ ដើម្បីធានាថាឯកសារនេះឆ្លុះបញ្ចាំងនូវកង្វល់ផ្សេងៗនៃបញ្ហាយេនឌ័រក្នុងក្របខ័ណ្ឌក្រសួងផែនការ ក៏ដូចជាក្នុងសង្គមកម្ពុជា និងសូមឧទ្ទិសកិច្ចខិតខំប្រឹងប្រែងនេះ ជូនចំពោះបុព្វការីជន វីរៈបុរស វីរៈនារី អ្នកដែលបានតស៊ូពលិកម្មគ្រប់ពេលវេលាដើម្បីបុព្វហេតុលើកស្ទួយតម្លៃស្ត្រីខ្មែរ និងថែរក្សាតម្លៃជាតិខ្មែរសម្រាប់មនុស្សជំនាន់ក្រោយៗ ។

**រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១០**

**ឆាយ ថន**

# មាតិកា


**បុព្វកថា** ............................................................ i

**មាតិកា** ............................................................ iii

**ជំពូកទី១ : សេចក្តីផ្តើម** ............................................................ ១

**ជំពូកទី២ : គោលនយោបាយដែលបានប្តេជ្ញាចិត្តដើម្បីសមភាពយេនឌ័រ** ............................................................ ៣

២.១ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ............................................................ ៣

២.២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ............................................................ ៤

២.៣ ផែនការយុទ្ធសាស្ត្រ នារីរតនៈទី៣ ............................................................ ៥

២.៤ ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផយផក) បច្ចុប្បន្នកម្ម ............................................................ ៦

២.៥ ក្រុមការងារយេនឌ័រក្រសួងផែនការ និង មន្ត្រីបង្គោលយេនឌ័រមន្ទីផែនការរាជធានី-ខេត្ត ....... ៧

២.៥.១ ក្រុមការងារយេនឌ័រក្រសួងផែនការ ............................................................ ៧

២.៥.២ មន្ត្រីបង្គោលយេនឌ័រ មន្ទីរផែនការរាជធានី-ខេត្ត ............................................................ ៨

**ជំពូកទី៣ : សមិទ្ធផលនិងបញ្ហាប្រឈម នៅក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្រនិងសកម្មភាពយេនឌ័រក្រសួងផែនការ ២០០៨-២០១០** ............................................................ ១០

៣.១ សកម្មភាពបញ្ជ្រាបយេនឌ័រក្នុងក្រសួងផែនការ ឆ្នាំ២០០៨............................................................ ១០

៣.១.១ ការបណ្តុះបណ្តាលយេនឌ័រដល់មន្ត្រីក្រសួងផែនការថ្នាក់ជាតិ ............................................................ ១០

៣.១.២ ការបណ្តុះបណ្តាលយេនឌ័រដល់មន្ត្រីផែនការនៅថ្នាក់ក្រោមជាតិ ............................................................ ១០

៣.១.៣ លទ្ធផលទទួលបាន ............................................................ ១១

៣.២ សកម្មភាពបញ្ជ្រាបយេនឌ័រក្នុងក្រសួងផែនការ ឆ្នាំ២០០៩ ............................................................ ១២

៣.៣ សកម្មភាពបញ្ជ្រាបយេនឌ័រក្នុងក្រសួងផែនការ ឆ្នាំ២០១០ ............................................................ ១២

៣.៤ ស្ថានភាពយេនឌ័រក្នុងក្រសួងផែនការ ............................................................ ១៣

**ជំពូកទី៤ : យុទ្ធសាស្ត្រនិងសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងក្រសួងផែនការ ២០០៩-២០១៣** .... ១៦

៤.១ គោលនយោបាយ ............................................................ ១៦

៤.២ យុទ្ធសាស្ត្រ ............................................................ ១៦

៤.៣ សកម្មភាព ............................................................ ១៧

## តារាង


តារាង ៣.១ : ចំនួនថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រសួងផែនការ នៅថ្នាក់ជាតិ ...................... ១៤

តារាង ៣.២ : ចំនួនមន្ត្រីរាជការក្នុងក្រសួងផែនការ នៅថ្នាក់មន្ទីរផែនការរាជធានី ខេត្ត និង ការិយាល័យផែនការស្រុក .................................................................. ១៤

តារាង ៣.៣ : កម្រិតអប់រំមន្ត្រីរាជការក្នុងក្រសួងផែនការ នៅថ្នាក់ជាតិ .......................... ១៥

តារាង ៣.៤ : ចំនួនមន្ត្រីរាជការក្រសួងផែនការដែលបានទទួលការបណ្តុះបណ្តាលនៅបរទេស ១៥

តារាង ៤.១ : ផែនការសកម្មភាពបញ្ជាបយេនឌ័រក្រសួងផែនការ ២០០៩-២០១៣ ...... ១៨


## ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ ១ : ប្រកាសស្តីពីការបង្កើតក្រុមការងារយេនឌ័រក្រសួងផែនការ ................................ ២៥

ឧបសម្ព័ន្ធ ២ : ប្រកាសស្តីពីការបង្កើតមន្ត្រីបង្គោលយេនឌ័រមន្ទីរផែនការរាជធានី-ខេត្ត .................. ២៨

ឧបសម្ព័ន្ធ ៣ : អង្គការលេខរបស់ក្រសួងផែនការ ........................................................................ ៣១

ឧបសម្ព័ន្ធ ៤ : អនុក្រឹត្យលេខ៥៥ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ . ៣២

ឧបសម្ព័ន្ធ ៥ : អនុក្រឹត្យលេខ ៨៥ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានមួយចំនួន ចំណុះវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ................................................................. ៤៣

ឧបសម្ព័ន្ធ ៦ : បញ្ជីរាយឈ្មោះអ្នកចូលរួមរៀបចំ *ផែនការយុទ្ធសាស្ត្របញ្ជាបយេនឌ័រ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ....... ៤៩

ឧបសម្ព័ន្ធ ៧ : ពាក្យបំព្រួញ ................................................................................................ ៥០

# ជំពូកទី១

## សេចក្តីផ្តើម

*រាជរដ្ឋាភិបាលកម្ពុជា* បានកំណត់នៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* និង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដោយចាត់ទុកស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ ។ នៅក្នុងអាណត្តិទី៣ នៃរដ្ឋសភា កន្លងទៅ *រាជរដ្ឋាភិបាល* បានអនុវត្ត ផែនការយុទ្ធសាស្ត្រ *"នារីរតនៈទី២"* ប្រកបដោយជោគជ័យ ស្របពេលនឹងការជំរុញ ការអនុម័តនិងអនុវត្តច្បាប់ ស្តីពី *ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ* និងច្បាប់ស្តីពី *ការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ* ។ ជាមួយគ្នានេះ ជាបណ្តើរៗ *រាជរដ្ឋាភិបាល* បានកាត់បន្ថយគម្លាតយេនឌ័រ លើកកម្ពស់តួនាទីនិងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និង បានការពារសិទ្ធិ របស់កម្មការិនី តាមរយៈ ការស្វែងរកការគាំទ្រមតិ និងការធ្វើអន្តរាគមន៍ផ្នែកគោលនយោបាយ ។ លើសពីនេះទៀត ស្ត្រីទទួលបាននូវ ជំនាញ សមត្ថភាព និងតួនាទី ដើម្បីចូលរួមកាន់តែច្រើនឡើង ក្នុងការដឹកនាំ និងការធ្វើសេចក្តីសម្រេចចិត្ត នៅគ្រប់កម្រិតនៃអភិបាលកិច្ច ។

គោលនយោបាយយេនឌ័ររបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់អាណត្តិទី៤ នៃរដ្ឋសភា ត្រូវបានកំណត់នៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣* និង ត្រូវបានបំបែកលម្អិតនៅក្នុង ផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ *"នារីរតនៈទី៣ ២០០៩-២០១៣"* ។ ជាផ្នែកមួយ នៃការអនុវត្តគោលនយោបាយនេះ ក៏ដូចជា ដំណើរការបញ្ជ្រាបយេនឌ័រក្នុងស្ថាប័នខ្លួន ក្រសួងផែនការបានបញ្ចូលសកម្មភាពយេនឌ័រជាយុទ្ធសាស្ត្រ ទៅក្នុងផែនការយុទ្ធសាស្ត្រ *"ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផយផក) បច្ចុប្បន្នកម្ម ២០០៩-២០១៣"* របស់ខ្លួន ។ ក្រៅពីសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងស្ថាប័ន និងខ្សែបណ្តោយរបស់ខ្លួន ក្រសួងផែនការ ដែលជាសេនាធិការរបស់ *រាជរដ្ឋាភិបាល* ក្នុងការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិ ក៏ត្រូវមានភារកិច្ចផងដែរ ក្នុងការបញ្ជ្រាបការងារយេនឌ័រ ទៅក្នុងបណ្តាគោលនយោបាយ និងផែនការ ដែលខ្លួនបានសម្របសម្រួលរៀបចំ ។

ដើម្បីឆ្លើយតបទៅនឹងការកំណត់របស់រាជរដ្ឋាភិបាល ដែលតម្រូវឱ្យធ្វើសង្គតិភាពអាណត្តិកាលរបស់ បណ្តាឯកសារ គោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រ ជាមួយនឹង របៀបវារៈគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់ក្រសួងកិច្ចការនារី ក្រសួងផែនការបានរៀបចំធ្វើបច្ចុប្បន្នភាព *"ផែនការយុទ្ធសាស្ត្រនិងសកម្មភាពបញ្ជ្រាបយេនឌ័រក្រសួងផែនការ ២០០៨-២០១០"* ឱ្យទៅជា *"ផែនការយុទ្ធ-សាស្ត្របញ្ជ្រាបយេនឌ័រ ក្រសួងផែនការ (ផយបយផក) បច្ចុប្បន្នកម្ម ២០០៩-២០១៣"* ។

*ផយបយផក បច្ចុប្បន្នកម្ម* នេះ រួមបញ្ចូលនូវបណ្តា គោលនយោបាយ យុទ្ធសាស្ត្រ និង សកម្មភាពមួយចំនួន ដែលមានចែងក្នុង *"ផែនការយុទ្ធសាស្ត្រនិងសកម្មភាពបញ្ជ្រាបយេនឌ័រក្រសួងផែនការ ២០០៨-២០១០"* ដែលមិនទាន់សម្រេចបាន និង បណ្តាសកម្មភាពបញ្ជ្រាបយេនឌ័រផ្សេងៗទៀត ដែលនឹងត្រូវអនុវត្ត ក្នុងអំឡុងពេល ពីឆ្នាំ ២០០៩ ដល់ ឆ្នាំ២០១៣ ។ ការអនុវត្ត *ផយបយផក បច្ចុប្បន្នកម្ម ២០០៩-២០១៣* គឺជាការរួមចំណែកក្នុងការអនុវត្ត *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ -- ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ -- ផែនការយុទ្ធសាស្ត្រនារីរតនៈទី៣ -- ផយផក បច្ចុប្បន្នកម្ម ២០០៩-២០១៣ --* និង *អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ)* សំដៅសម្រេចបាននូវ *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក)* ។

*ផយបយផក បច្ចុប្បកម្ម ២០០៩-២០១៣* ត្រូវបានរៀបចំឡើង ដោយផ្អែកលើ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* លទ្ធផលនៃការអនុវត្ត *ផែនការយុទ្ធសាស្ត្រនិងសកម្មភាពបញ្ជ្រាបយេនឌ័រក្រសួងផែនការ ២០០៨-២០១០* និង អាទិភាពនៃការងារយេនឌ័រ ដែលត្រូវអនុវត្តក្នុងអំឡុងពេលពីឆ្នាំ២០០៩-២០១៣ ។ ផែនការនេះ ត្រូវបានរៀបចំឡើងដោយក្រុមការងារយេនឌ័រក្រសួងផែនការ និងមានការចូលរួមយ៉ាងទូលំទូលាយពីអ្នកដែលមានចំណែកពាក់ព័ន្ធ ។ *ផយបយផក បច្ចុប្បកម្ម ២០០៩-២០១៣* ត្រូវបានអនុម័តដោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០ ។

# ជំពូកទី២

## គោលនយោបាយដែលបានប្តេជ្ញាចិត្តទៅនឹងសមភាពយេនឌ័រ

### ២.១ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២

បន្ទាប់ពី*ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ* ដែលបានប្រព្រឹត្តទៅ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ *រាជរដ្ឋាភិបាលកម្ពុជា* បានប្រកាសចេញនូវ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ដែលជារបៀបវារៈគោល-នយោបាយសង្គម សេដ្ឋកិច្ចនៃ *កម្មវិធីនយោបាយ* របស់ខ្លួន សម្រាប់ នីតិកាលទី៤ នៃរដ្ឋសភា (២០០៨-២០១៣) ។ យុទ្ធសាស្ត្រនេះ ត្រូវបានប្រកាសជាផ្លូវការ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងកិច្ចប្រជុំលើកដំបូងរបស់គណៈរដ្ឋមន្ត្រី នៃ*រាជរដ្ឋាភិបាល* ថ្មី ។ នៅក្នុងឱកាសនោះ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ត្រូវបានបង្ហាញឱ្យឃើញថា ជាឯកសារមួយដែលត្រូវបានរៀបចំឡើង ដោយ ការធ្វើបច្ចុប្បន្នភាព ការសម្រិតសម្រាំង និងការសម្រួចបន្ថែម នូវគោលនយោបាយទាំងឡាយ ដែលបានកំណត់នៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១* សំដៅរំលេចឱ្យចេញជាកញ្ចប់អាទិភាព នៅតាមបណ្តាវិស័យគន្លឹះ ដែលមានលក្ខណៈ ជាប្រព័ន្ធ ស៊ីចង្វាក់ប្រទាក់ក្រឡាគ្នា និង យោងគ្នាទៅវិញទៅមក ។

*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* បានលើកឡើងជាលម្អិត នូវគោលនយោបាយជាអាទិភាពសម្រាប់ការអនុវត្តកម្មវិធីកំណែទម្រង់នានារបស់*រាជរដ្ឋាភិបាលកម្ពុជា* សំដៅ លើកកម្ពស់សមត្ថភាពស្ថាប័ន ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច និង បង្កើតបរិយាកាសអំណោយផល សម្រាប់ទាក់ទាញការវិនិយោគពីប្រភពក្នុងនិងក្រៅប្រទេស ក្នុងទិសដៅ បង្កើតកាលានុវត្តភាពការងារសម្រាប់ប្រជាជនកម្ពុជា កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍវិស័យសំខាន់ៗរបស់សេដ្ឋកិច្ចជាតិ ។

តាមរយៈ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* នេះ រាជរដ្ឋាភិបាលកម្ពុជាបានបន្តផ្តល់អាទិភាពខ្ពស់លើការអនុវត្តគោលនយោបាយសមភាពយេនឌ័រ (មុំទី៣ នៃចតុកោណទី៤ : *ការកសាងសមត្ថភាពនិងការអភិ-វឌ្ឍធនធានមនុស្ស*) ។ តាមរយៈការផ្តល់អាទិភាពនេះ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តអនុវត្តគោលនយោបាយបង្កើនកាលានុវត្តភាព ឱ្យសិស្ស-និស្សិតនារី បានចូលរៀនឱ្យបានកាន់តែច្រើន តាមរយៈ ការបង្កើនការផ្តល់អាហា-រូបករណ៍កាន់តែច្រើន សម្រាប់សិស្ស-និស្សិតនារី ការផ្តល់កម្មវិធីបំប៉ននៅ សាលារៀន គ្រឹះស្ថានសិក្សា ការផ្តល់កន្លែងស្នាក់នៅនិងការធានាដឹកជញ្ជូនទៅមកប្រកបដោយសុវត្ថិភាព សម្រាប់សិស្ស-និស្សិតនារី និងការបង្កើន

ចំនួនគ្រូបង្រៀនជាស្ត្រី ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបន្តលើកតម្កើងតួនាទីរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចចិត្ត និង យកចិត្តទុកដាក់លើការបណ្តុះបណ្តាល មុខជំនាញដល់ស្ត្រីនៅគ្រប់កម្រិត ។ *រាជរដ្ឋាភិបាលកម្ពុជា* នឹងបង្កើន តួនាទី និងសមត្ថភាពរបស់ស្ត្រី ឱ្យបានជាអតិបរមា នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តស្ថាប័នជាតិគ្រប់ថ្នាក់ ដោយ បន្តពង្រីកឱកាសការងារសម្រាប់ស្ត្រី និងណែនាំបណ្តុះបណ្តាលអំពីរបៀបនៃការតស៊ូមតិ ក្នុងការឈរឈ្មោះនៅ តាមបណ្តាភូមិ-ឃុំ ទូទាំងប្រទេស ព្រមទាំង ការការពារសិទ្ធិធ្វើការងាររបស់ពួកគាត់ ។

ដើម្បីទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី និងការជួញដូរមនុស្ស *រាជរដ្ឋាភិបាលកម្ពុជា* នឹងអនុវត្តឱ្យបាន ខ្ជាប់ខ្ជួននូវ *ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការការពារជនរងគ្រោះ* សម្រាប់ផ្តល់នូវការការពារ ស្របច្បាប់យ៉ាងមានប្រសិទ្ធភាពនិងទាន់ពេលវេលា ដល់ជនរងគ្រោះដែលភាគច្រើនជាស្ត្រីនិងកុមារ ដោយមាន ការចូលរួមសហការ ពីគ្រប់ស្ថាប័នពាក់ព័ន្ធ ជាពិសេស ពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងបណ្តាដៃគូ នានា ។

## ២.២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣

*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣* គឺជាឯកសារគោល-នយោបាយ រយៈពេលមធ្យម និងជាឧបករណ៍ ឬផែនទីចង្អុលផ្លូវមួយ សម្រាប់ការអនុវត្តនូវ បណ្តាគោលនយោ-បាយអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ដែលបានលើកឡើងនៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ។ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវរៀបចំឡើង ដើម្បីសម្រេចគោលដៅចម្បងពីរ ។ *គោលដៅទី១* គឺ ដើម្បីបន្សុីអាណត្តិកាលរបស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ជាមួយអាណត្តិរបស់ *រាជរដ្ឋាភិបាល* សម្រាប់ *នីតិកាលទី៤ នៃរដ្ឋសភា* សំដៅធានាថា សកម្មភាពដែលបានគ្រោងទុកទាំងឡាយរបស់ ក្រសួង ស្ថាប័ន ទាំងអស់ ត្រូវបានរៀបចំឡើង ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយរបស់ *រាជរដ្ឋាភិបាលកម្ពុជា* ដែល ត្រូវបានកំណត់នៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ។ *គោលដៅទី២* គឺ ដើម្បីធានាថា ការងារដែល ត្រូវលើកឡើង ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងនេះ ត្រូវបានរៀបចំ ដោយមានការគិតគូរដល់ ផលប៉ះពាល់នៃការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ដែលអាចមានមកលើសេដ្ឋកិច្ចកម្ពុជា ។

ដើម្បីរៀបចំ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* វិធីសាស្ត្រនៃការរៀបចំផែនការ ត្រូវបានកែលម្អ។ វិធីសាស្ត្រនៃការកែលម្អ ផ្តោតលើគោលគំនិតសំខាន់ៗ ដូចជា ការកំណត់ថា (១) *តើក្រសួង ស្ថាប័នណា* ជាអ្នក ទទួលខុសត្រូវ ក្នុងការអនុវត្តគោលនយោបាយអាទិភាពទាំងឡាយ នៅក្នុងមុំនីមួយៗនៃ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* (២) *តើសកម្មភាពជាក់លាក់អ្វីខ្លះ* ដែលក្រសួង ស្ថាប័នទទួលខុសត្រូវ បានគ្រោងឡើង ដើម្បី អនុវត្តគោលនយោបាយ អាទិភាពទាំងឡាយ និង (៣) *តើតម្លៃប៉ុន្មាន* ដែលក្រសួង ស្ថាប័នទទួលខុសត្រូវ ត្រូវ ប៉ាន់ស្មានឱ្យបានត្រឹមត្រូវបំផុត ដើម្បីអនុវត្តសកម្មភាពទាំងឡាយ ដែលបានគ្រោងសម្រាប់អំឡុងឆ្នាំ២០០៩-

២០១៣ ។ ជាមួយគ្នានេះ វិធីសាស្ត្រនេះបានលើកឡើងនូវ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សម្រាប់ *ផយអជ បច្ចុប្បន្នកម្ម* ដើម្បីរំលេចឡើងនូវវិធីសាស្ត្រពីលើចុះក្រោមនៃការធ្វើផែនការ ដែលត្រូវបានរៀបចំឡើង ដោយផ្អែកលើការវិភាគតាមរបៀបសេដ្ឋកិច្ចមាត្រ អំពីស្ថានភាពមួយដែលអាចមានសម្រាប់កំណើនសេដ្ឋកិច្ច អំពីតម្រូវការវិនិយោគ "មូលធន" ដើម្បីសម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ចដែលបានគ្រោងទុក និងអំពីស្ថានភាពចំណូល និងចំណាយថវិកា សម្រាប់ដំណាក់កាលរបស់ផែនការ ។ វិធីសាស្ត្រនេះ ក៏បង្ហាញផងដែរពី ការរៀបចំកម្មវិធី ឬការវិភាជន៍ និងចំណាយអភិវឌ្ឍន៍សរុប ។

*ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវបានរៀបចំជាប្រាំពីរជំពូក ដែលក្នុងនោះ បញ្ហាយេនឌ័រត្រូវបាន បញ្ជ្រាបទៅក្នុងគ្រប់ផ្នែក និងវិស័យទាំងអស់ នៃឯកសារនេះ ។ បន្ថែមលើការបញ្ជ្រាបនៅគ្រប់ផ្នែកនេះ សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ នៅក្នុងការអនុវត្តគោលនយោបាយសមភាពយេនឌ័រ ក្នុងដំណាក់កាលពីឆ្នាំ២០០៦-២០០៨ ត្រូវបានលើកឡើងក្នុង ចំណុច ៦.៣ នៃជំពូកទី២ ហើយ គោលនយោបាយ និងសកម្មភាពចម្បងៗ ទាក់ទងនឹងសមភាពយេនឌ័រ ដែលត្រូវអនុវត្តក្នុងអាណត្តិទី៤ នៃរដ្ឋសភា (២០០៩-២០១៣) ត្រូវបានលើកឡើងនៅក្នុងចំណុច ៦.៣ នៃជំពូកទី៤ ។ គោលនយោបាយ និងសកម្មភាពអាទិភាពចម្បងៗ ដែលទាក់ទងនឹងយេនឌ័រនេះ បានផ្តោតជាសំខាន់លើវិស័យជាយុទ្ធសាស្ត្រចំនួន ៥ កម្មវិធីបញ្ជ្រាបយេនឌ័រ ទៅក្នុងគោលនយោបាយជាតិនិងតាមវិស័យ កម្មវិធីកែទម្រង់និងការអនុវត្តអនុសញ្ញាអន្តរជាតិ ព្រមទាំង ការដោះស្រាយការគ្រប់គ្រងជាយុទ្ធសាស្ត្រ ការអភិវឌ្ឍសមត្ថភាព និងប្រសិទ្ធភាពជំនួយ ដែលមានលក្ខណៈអន្តរវិស័យ ។ គោលនយោបាយទាំងនេះ ក៏បានលើកឡើងផងដែរ ពីកម្មវិធីបញ្ជ្រាបយេនឌ័រ និង ផ្នែកអន្តរវិស័យនៃការគ្រប់គ្រងយុទ្ធសាស្ត្រផ្ទៃក្នុងការអភិវឌ្ឍសមត្ថភាព និងការធ្វើឱ្យប្រសើរឡើងប្រសិទ្ធភាពជំនួយ ។

## ២.៣ ផែនការយុទ្ធសាស្ត្រ "នារីរតនៈទី៣"

*នារីរតនៈទី៣* គឺជាផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ (២០០៩-២០១៣) សម្រាប់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅកម្ពុជា ។ *ផែនការយុទ្ធសាស្ត្រនារីរតនៈទី៣* ត្រូវបានរៀបចំឡើង ដើម្បីបន្តការចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅកម្ពុជា ។ មូលដ្ឋានគ្រឹះនៃការរៀបចំយុទ្ធសាស្ត្រនេះ គឺផ្អែកលើលទ្ធផលនៃការអនុវត្ត *ផែនការយុទ្ធសាស្ត្រនារីរតនៈទី២ (២០០៤-២០០៨)* និងឯកសារប៉ាន់ប្រមាណ អំពីយេនឌ័រនៅកម្ពុជាឆ្នាំ២០០៨ *"ចំណែកស្មើភាពសម្រាប់នារី"* ។

*ផែនការយុទ្ធសាស្ត្រនារីរតនៈទី៣* បានរួមចំណែកក្នុងការបញ្ជ្រាបយេនឌ័រ ទៅក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ជាមួយគ្នានេះ *ផែនការយុទ្ធសាស្ត្រនារីរតនៈទី៣* ក៏បានចូលរួម និងផ្សារ

ភ្ជាប់ ជាមួយនឹង ការអនុវត្តគោលនយោបាយ និងផែនការជាតិ សំខាន់ៗ ដូចជា *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក) -- ផយអជ បច្ចុប្បន្នកម្ម -- គោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នា -- ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី* ។ល។ លើសពីនេះទៀត *ផែនការយុទ្ធសាស្ត្រនារីរតនៈទី៣* ក៏ឆ្លើយតបទៅនឹងបញ្ហាអភិវឌ្ឍន៍សំខាន់ៗនៅក្នុងប្រទេសកម្ពុជា និង ចូលរួមជាមួយកិច្ចសហប្រតិបត្តិការ និងការប្តេជ្ញាចិត្តជាតិនិងអន្តរជាតិ ផងដែរ ។

ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានចែកចេញជាប្រាំផ្នែក និងឧបសម្ព័ន្ធម៉ាទ្រីសផែនការសកម្មភាព ។ *ផែនការយុទ្ធសាស្ត្រនារីរតនៈទី៣* ផ្តោតលើវិស័យជាយុទ្ធសាស្ត្រចំនួន ៥ ដែលមានគោលដៅបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី -- អប់រំនិងផ្លាស់ប្តូរ ឥរិយាបថនិងអាកប្បកិរិយា ស្ត្រីនិងក្មេងស្រី -- ការពារស្ត្រីនិងក្មេងស្រី តាមផ្លូវច្បាប់ -- លើកកម្ពស់សុខភាពនិងអាហារូបត្ថម ដល់ស្ត្រីនិងក្មេងស្ត្រី និងទប់ស្កាត់ការរីករាលដាលជំងឺអេដស៍ -- និង បង្កើនការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងវិស័យសាធារណៈនិងនយោបាយ ។ ផែនការយុទ្ធសាស្ត្រទាំងនេះ ក៏បានផ្តោតលើកម្មវិធីបញ្ជ្រាបយេនឌ័រទៅក្នុងផ្នែកចំនួន ៤ គឺ ទៅក្នុង គោលនយោបាយជាតិ -- កម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល -- វិស័យពាក់ព័ន្ធនានា -- និង ការអនុវត្ត*អនុសញ្ញាស្តីពីការទប់ស្កាត់រាល់ទម្រង់រើសអើងលើស្ត្រីភេទ* ។ ផ្នែកទី៣ នៃ *ផែនការយុទ្ធសាស្ត្រនារីរតនៈទី៣* (ផ្នែកសំខាន់នៃឯកសារ) បានលើកឡើងលម្អិត ពី វិស័យជាយុទ្ធសាស្ត្រទាំង៥ -- កម្មវិធីសំខាន់ៗទាំង៤ សម្រាប់បញ្ជ្រាបយេនឌ័រ -- និងផ្នែកអន្តរវិស័យ ដែលរួមមាន ការគ្រប់គ្រងជាយុទ្ធសាស្ត្រ ការអភិវឌ្ឍសមត្ថភាព និង ប្រសិទ្ធភាពនៃជំនួយ ។

## ២.៤ ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផយផក) បច្ចុប្បន្នកម្ម ២០០៩-២០១៣

ក្រសួងផែនការមានភារកិច្ច សម្របសម្រួល ប្រមូលចងក្រង វិភាគ និងផ្សព្វផ្សាយ ស្ថិតិផ្លូវការ ប្រកបដោយគុណភាពខ្ពស់ ដើម្បីគាំទ្រដល់ការផ្តល់ពត៌មានសម្រាប់ការធ្វើ សេចក្តីសម្រេចចិត្ត ជជែកវែកញែក និងពិភាក្សានៅក្នុងរាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន អ្នកជំនួញ និង ប្រព័ន្ធឃោសនា ព្រមទាំងសហគមន៍ជាតិនិងអន្តរជាតិ ។ ក្រសួងផែនការក៏មានភារកិច្ច ដឹកនាំ សហការ និងសម្របសម្រួល ជាមួយ អ្នកដែលមានចំណែកពាក់ព័ន្ធ ក្នុងនិងក្រៅរាជរដ្ឋាភិបាល ដើម្បី រៀបចំ គោលនយោបាយ យុទ្ធសាស្ត្រ និង ផែនការ នៅកម្រិតជាតិ (រួមទាំង ការរៀបចំ *ផយអជ*) ធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃពី ការអនុវត្តផែនការជាតិ តាមរយៈ *ការរៀបចំ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ* និង*របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ* ក៏ដូចជា ពី វឌ្ឍនភាពឆ្ពោះទៅសម្រេច *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក)* ។ ជាមួយគ្នានេះ ក្រសួងផែនការក៏មានភារកិច្ច ផ្តល់នូវ ការណែនាំនិងការគាំទ្រផ្នែកបច្ចេកទេស ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាឱ្យទទួលបាននូវកិច្ចសហប្រតិបត្តិការល្អ ពីក្រសួង ស្ថាប័នទាំងនោះ ព្រមទាំង ពីគ្រប់ភាគីដែលមានចំណែកពាក់ព័ន្ធទាំងអស់ នៅក្នុងដំណើរការរៀបចំ គោលនយោបាយ យុទ្ធសាស្ត្រ និង ផែនការ ។ ក្រៅពីភារកិច្ចសម្របសម្រួលនិងណែនាំនេះ

ក្រសួងផែនការ ក៏មានភារកិច្ច រៀបចំនិងអនុវត្ត កម្មវិធីនិងគម្រោងនានា ដើម្បីអនុវត្តតួនាទីដែលត្រូវបានកំណត់សម្រាប់ក្រសួងផែនការ ដើម្បីគាំទ្រដល់សកម្មភាពកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាលកម្ពុជា ។ បន្ថែមលើតួនាទីភារកិច្ច ដែលបានលើកឡើងខាងលើ ក្រសួងផែនការ បាននិងកំពុងជំរុញ ការបញ្ជ្រាបយេនឌ័រក្នុងផែនការ កសាងសមត្ថភាពដើម្បីបញ្ជ្រាបយេនឌ័រក្នុងផែនការ តាមរយៈ ការរៀបចំការបណ្តុះបណ្តាលពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ និង រៀបចំនិងអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ ។

ដើម្បីអនុវត្តតួនាទីភារកិច្ចទាំងនេះ ក្រសួងផែនការបានរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួន មានឈ្មោះថា "*ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផយផក) បច្ចុប្បន្នកម្ម ២០០៩-២០១៣*" ។ ផែនការនេះ ត្រូវបានរៀបចំឡើង ដោយធ្វើបច្ចុប្បន្នភាព *ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផយផក) ២០០៦-២០១០* ដើម្បីធ្វើសង្គតិភាពអាណត្តិផែនការនេះ ទៅនឹងអាណត្តិកាលរបស់ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* និង *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* និងដើម្បី រួមចំណែកអនុវត្តគោលដៅអាទិភាពរបស់ *រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា* ។

*ផយផក បច្ចុប្បន្នកម្ម* គឺជាឯកសារយោងតែមួយគត់ សម្រាប់ឱ្យអ្នកដែលមានចំណែកពាក់ព័ន្ធ ហើយមានចំណាប់អារម្មណ៍ ក្នុងការជួយធ្វើឱ្យប្រសើរឡើង នូវការងារផែនការនិងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ *ផយផក បច្ចុប្បន្នកម្ម* បានបង្កើតគោលនយោបាយនិងយុទ្ធសាស្ត្រ សម្រាប់ការងារនេះ ដើម្បីកំណត់អាទិភាព និងប្រមូលផ្តុំ គោលដៅ ទិសដៅ និងសកម្មភាពសំខាន់ៗនានា របស់ក្រសួងផែនការ សម្រាប់រយៈពេល ពីឆ្នាំ ២០០៩-ដល់ ២០១៣ ។

ជារួម *ផយផក បច្ចុប្បន្នកម្ម* ចែកជា បីផ្នែក សកម្មភាពរបស់អគ្គនាយកដ្ឋានផែនការ សកម្មភាពរបស់វិទ្យាស្ថានជាតិស្ថិតិ និងសកម្មភាពរួម ដែលសរុបមាន ៨ទិសដៅ ១៩ចំណុចដៅ និងជាង ៨២សកម្មភាពការងារ ។ ក្នុងផ្នែកទី៣ (សកម្មភាពរួម) គឺជាបណ្តាសកម្មភាពសំខាន់ៗ ដែលទាក់ទងនឹង ការកសាងសមត្ថភាពស្ថាប័នក្រសួងផែនការ ដើម្បីផ្តល់អាទិភាពនិងបញ្ជ្រាបការងារយេនឌ័រទៅក្នុង គោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និង កម្មវិធី ។

## ២.៥ ក្រុមការងារយេនឌ័រក្រសួងផែនការ និង មន្ត្រីបង្គោលយេនឌ័រមន្ទីរផែនការរាជធានី-ខេត្ត

### ២.៥.១ ក្រុមការងារយេនឌ័រក្រសួងផែនការ

ក្រុមការងារយេនឌ័រក្រសួងផែនការត្រូវបានបង្កើតឡើងនៅ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៥ តាមរយៈប្រកាសលេខ ១៦៥ ប្រក.ផក ដឹកនាំដោយរដ្ឋលេខាធិការម្នាក់ និង មានសមាជិកចំនួន ២២នាក់ ដែលជាតំណាងមកពីគ្រប់នាយកដ្ឋាន ក្នុងក្រសួងផែនការ ។ មូលហេតុនៃការបង្កើតក្រុមការងារបញ្ជ្រាបយេនឌ័រនេះ គឺ ដោយសារ

បញ្ហាយេនឌ័រត្រូវបានចាត់ទុកជាបញ្ហាអាទិភាព ក្នុង គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី ទាំងឡាយ របស់ក្រសួងផែនការ និងដើម្បី កែលម្អសមភាពនិងសមធមិយេនឌ័រក្នុងក្រសួងផែនការ ។ យោងតាមភាពចាំបាច់ និងដើម្បីតម្រូវទៅតាមតួនាទីរបស់សមាជិកនីមួយៗ ក៏ដូចជា ដើម្បីពន្លឿនដំណើរការបញ្ជ្រាបយេនឌ័រក្នុងក្រសួងផែនការ ប្រកាសនេះ ត្រូវបានកែសម្រួលឡើងវិញ ជាច្រើនលើកច្រើនសារ ។ ការកែសម្រួលចុងក្រោយ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០ តាមរយៈ ប្រកាសរបស់ក្រសួងផែនការ លេខ ១៤៤ ប្រក.ផក ។ តាមរយៈការកែសម្រួលនេះ សមាសភាពក្រុមការងារយេនឌ័រក្រសួងផែនការនាពេលបច្ចុប្បន្ន មានចំនួន ២៣រូប ( ក្នុងនោះប្រុសមាន ចំនួន ១១រូប និង ស្រីចំនួន ១២រូប) ។ ក្រុមការងារនេះ មាន ភារកិច្ចដូចតទៅ :

១. ធ្វើការបញ្ជ្រាបទស្សនយេនឌ័រ ទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធី ដែលត្រូវបានរៀបចំ ឡើងដោយក្រសួងផែនការ ។
២. ធ្វើការបណ្តុះបណ្តាលពីការបញ្ជ្រាបយេនឌ័រ ក្នុងក្រសួងផែនការ និងមន្ទីរផែនការរាជធានី-ខេត្ត ។
៣. ធ្វើការសម្របសម្រួលវគ្គបណ្តុះបណ្តាល សិក្ខាសាលា ស្តីពីការបញ្ជ្រាបយេនឌ័រ ដែលទាក់ទងនឹងសកម្មភាពផែនការជាក់លាក់ ។
៤. ធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលចំណេះដឹង ផ្នែកយេនឌ័រ ក្នុងក្រសួងផែនការ ថ្នាក់កណ្តាល និងតាមបណ្តារាជធានី-ខេត្ត និងមូលដ្ឋាន ។
៥. ធ្វើទំនាក់ទំនងនិងសហការ ជាមួយក្រុមការងារយេនឌ័រក្រសួងកិច្ចការនារី ដើម្បីរៀបចំនិងអនុវត្តការងារផ្សេងៗ ទាក់ទងនឹងការងារយេនឌ័រ ។
៦. សម្របសម្រួល និងស្វែងរកការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ពី ក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ ដើម្បី ដំណើរការការងារ និងលើកកម្ពស់ការងារយេនឌ័រក្នុងក្រសួងផែនការ ។
៧. ធ្វើរបាយការណ៍ស្តីពីស្ថានភាពយេនឌ័រ និងសកម្មភាពដែលក្រុមការងារយេនឌ័រអនុវត្ត ក្នុងនិងក្រៅក្រសួងផែនការ ដល់ថ្នាក់ដឹកនាំក្រសួង ។
៨. ធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ពីការងារអនុវត្តពាក់ព័ន្ធ នឹងការងារយេនឌ័រ ។

ប្រកាសស្តីពីការបង្កើតក្រុមការងារយេនឌ័រក្រសួងផែនការ មានបង្ហាញជូន នៅក្នុងឧបសម្ព័ន្ធ ១ ។

### ២.៥.២ មន្ត្រីបង្គោលយេនឌ័រមន្ទីរផែនការរាជធានី-ខេត្ត

បន្ថែមលើប្រកាសស្តីពីការបង្កើតក្រុមការងារយេនឌ័រ នេះ ក្រសួងផែនការក៏បានរៀបចំប្រកាសលេខ ១៤៥ ប្រក.ផក ស្តីពី ការបង្កើតមន្ត្រីបង្គោលយេនឌ័រប្រចាំនៅរាជធានី-ខេត្ត ដែលមានមន្ត្រីបង្គោលយេនឌ័រពីគ្រប់មន្ទីរផែនការ រាជធានី-ខេត្ត សរុបចំនួន ២៤រូប ( ប្រុស ០៧នាក់ និងស្រី ១៧នាក់) ។ ប្រកាសនេះ ត្រូវបាន

ចុះហត្ថលេខាដោយ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០ ។ មន្ត្រីបង្គោល រាជធានី ខេត្ត នីមួយៗ មានភារកិច្ច :

១. បញ្ជ្រាបទស្សនៈយេនឌ័រទៅក្នុងគ្រប់ផែនការ គោលនយោបាយ កម្មវិធី ដែលត្រូវបានរៀបចំឡើងដោយក្រសួងផែនការ

២. បណ្តុះបណ្តាលអំពីការបញ្ជ្រាបយេនឌ័រក្នុងមន្ទីរផែនការ រាជធានី-ខេត្ត

៣. សម្របសម្រួល វគ្គបណ្តុះបណ្តាល សិក្ខាសាលា ស្តីពីការបញ្ជ្រាបយេនឌ័រ ដែលទាក់ទងទៅនឹងសកម្មភាព ផែនការជាក់លាក់

៤. ផ្សព្វផ្សាយ និងបណ្តុះបណ្តាលចំណេះដឹងផ្នែកយេនឌ័រ ក្នុងមន្ទីរផែនការរាជធានី ខេត្ត និងតាមមូលដ្ឋាន

៥. ធ្វើទំនាក់ទំនង និងសហការជាមួយក្រុមការងារយេនឌ័រក្រសួងផែនការ មន្ទីរកិច្ចការនារី នៃក្រសួងកិច្ចការនារី និង ក្រសួងផែនការ ដើម្បីរៀបចំនិងអនុវត្ត ការងារផ្សេងៗទាក់ទងនឹងបញ្ហាយេនឌ័រ

៦. ផ្តល់របាយការណ៍ជាប្រចាំ ពីសកម្មភាពនានាទាក់ទងការងារយេនឌ័រ មកក្រុមការងារយេនឌ័រក្រសួងផែនការ និងថ្នាក់ដឹកនាំក្រសួង

៧. ទទួលការងារចាំបាច់មួយចំនួនទៀត ដែលទាក់ទងការងារយេនឌ័រ ។

ប្រកាសស្តីពីការបង្កើតមន្ត្រីបង្គោលយេនឌ័រមន្ទីរផែនការរាជធានី-ខេត្ត មានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធ ២ ។

# ជំពូកទី៣

# សមិទ្ធផលនិងបញ្ហាប្រឈម នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនិងសកម្មភាព បញ្ហាបយេនឌ័រក្រសួងផែនការ ២០០៨-២០១០

ដោយមានការគាំទ្រពីថ្នាក់ដឹកនាំក្រសួងផែនការ និងកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានា ក្រសួងផែនការបានបង្កើតក្រុមការងារយេនឌ័រក្រសួងផែនការ និងការរៀបចំ *ផែនការយុទ្ធសាស្ត្រនិងសកម្មភាពបញ្ជ្រាបយេនឌ័រក្រសួងផែនការ ២០០៨-២០១០* ដោយជោគជ័យ ។ សមិទ្ធផលជាច្រើនដែលសម្រេចបាន តាមរយៈការអនុវត្តផែនការនេះ រួមមាន :

## ៣.១ សកម្មភាពបញ្ជ្រាបយេនឌ័រក្នុងក្រសួងផែនការ ឆ្នាំ២០០៨

ទន្ទឹមនឹងការរៀបចំ *ផែនការយុទ្ធសាស្ត្រនិងសកម្មភាពបញ្ជ្រាបយេនឌ័រ ២០០៨-២០១០* ក្រុមការងារយេនឌ័រក្រសួងផែនការ ក៏បានត្រៀមលក្ខណៈក្នុងការអនុវត្តផែនការនេះ ជាបន្ទាន់ផងដែរ ។ ដោយមានកិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ ពី *មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន* វគ្គបណ្តុះបណ្តាលស្តីពី *ការបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិ* ដល់គ្រូបង្គោល ត្រូវបានរៀបចំឡើង កាលពីថ្ងៃទី៣០ ខែមិថុនា ដល់ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៨ នៅខេត្តសៀមរាប ដើម្បីបំប៉នចំណេះដឹងស្តីពីបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិ ដល់សមាជិកក្រុមការងារយេនឌ័រក្រសួងផែនការ ។ ក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាលនេះ គ្រូបង្គោល ចំនួន ៨នាក់ ត្រូវបានជ្រើសរើសចេញ ពីក្នុងចំណោមសមាជិកក្រុមការងារយេនឌ័រចំនួន ២២នាក់ ដែលបានទទួលការបណ្តុះបណ្តាល សម្រាប់ធ្វើការបណ្តុះបណ្តាលបន្ត ដល់មន្ត្រីផែនការផ្សេងទៀត ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ។

### ៣.១.១ ការបណ្តុះបណ្តាលយេនឌ័រដល់មន្ត្រីក្រសួងផែនការថ្នាក់ជាតិ

ដើម្បីធ្វើការបណ្តុះពណ្តាលបន្តដល់ មន្ត្រីផ្សេងទៀត ទាំងនៅថ្នាក់ជាតិ និងថ្នាកក្រោមជាតិ គ្រូបង្គោលដែលបានជ្រើសរើស ត្រូវបានចែកចេញជាពីរក្រុម ។ ការបណ្តុះបណ្តាលនៅក្រសួងផែនការ បានចាប់ផ្តើមពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ដែលមាន ០៥ថ្នាក់ ចែកចេញជាបីវគ្គ ហើយវគ្គនីមួយៗ មានរយៈពេល ៣ថ្ងៃ ។ សមាសភាពអ្នកចូលរួម មានចាប់ពីមន្ត្រីថ្នាក់ ប្រធាននិងអនុប្រធានការិយាល័យ ប្រធាននិងអនុប្រធាននាយកដ្ឋាន និង អគ្គនាយករង សរុបចំនួន ១៥០នាក់ ។

### ៣.១.២ ការបណ្តុះបណ្តាលយេនឌ័រដល់មន្ត្រីក្រសួងផែនការថ្នាក់ក្រោមជាតិ

ការបណ្តុះបណ្តាលនៅថ្នាក់ក្រោមជាតិ ត្រូវបានធ្វើឡើងចំនួន ៨វគ្គ (វគ្គបណ្តុះបណ្តាលនីមួយៗមានរយៈពេល ៣ថ្ងៃ) ចាប់ពីថ្ងៃទី០៨ ខែតុលា ដល់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ នៅក្នុងខេត្តគោលដៅចំនួន ០៨ រួម

មាន ខេត្តកំពង់ឆ្នាំង កំពង់ចាម ស្ទឹងត្រែង កែប កោះកុង ព្រៃវែង បាត់ដំបង និង ខេត្តសៀមរាប ។ សមាសភាពនៃអ្នកចូលរួម មានចាប់ពីមន្ត្រីថ្នាក់ ប្រធាននិងអនុប្រធានការិយាល័យ និង ប្រធាននិងអនុប្រធានមន្ទីរផែនការ រាជធានី ខេត្ត មកពីមន្ទីរផែនការរាជធានី ខេត្ត ទាំង២៤ សរុបចំនួន ២៤០នាក់ ។

## គោលបំណងនៃវគ្គបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងផ្តល់ឱ្យអ្នកចូលរួម យល់ដឹងពី :

១. ការវិភាគយេនឌ័រក្នុងសហគមន៍ ឬក្នុងគម្រោង និង ការកំណត់បញ្ហាយេនឌ័រ

២. ការកំណត់ពីឧបស័គ្គដែលរារាំងការចូលរួមរបស់ស្ត្រីនៅក្នុងដំណើការផែនការ

៣. ការបញ្ចូលទស្សនៈយេនឌ័រក្នុងផែនការ និងដំណើរការតាមដានត្រួតពិនិត្យ

៤. ការបង្កើតសូចនាករឆ្លើយតបនឹងតម្រូវការយេនឌ័រ

## ប្រធានបទ ក្នុងវគ្គសិក្សាការបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិ

ប្រធានបទ ដែលត្រូវបាន និងពិភាក្សាក្នុងវគ្គបណ្តុះបណ្តាល រួមមាន :

១. យេនឌ័រជាអ្វី? ហេតុអ្វីបានជាចាំបាច់ត្រូវមានយេនឌ័រក្នុងផែនការ?

២. យេនឌ័រ និង ភាពក្រីក្រ (វិភាគទំនាក់ទំនងសមភាពយេនឌ័រទៅនឹងភាពក្រីក្រ ផលប៉ះពាល់ដល់ស្ត្រី)

៣. ដំណោះស្រាយផ្នែកសិទ្ធចំពោះយេនឌ័រ និង ភេទ ( អនុសញ្ញា ស៊ី-ដ)

៤. ការបែងចែកពលកម្មតាមយេនឌ័រ ការទទួលបាន និង ការគ្រប់គ្រងធនធាន

៥. តម្រូវការយេនឌ័រ

៦. ការចូលរួមរបស់ស្ត្រីក្នុងដំណើរការរៀបចំផែនការ

៧. ផែនការជាអ្វី? ផែនការដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ

៨. សូចនាករយេនឌ័រ និង ស្ថិតិ

៩. កំណត់បញ្ហាយេនឌ័រដោយប្រើប្រាស់ស្ថិតិជាតិ

១០. ផែនការសកម្មភាព ( សិក្ខាកាមផ្សារភ្ជាប់ចំណេះដឹងដែលបានទទួលការបណ្តុះបណ្តាលរយៈពេលបីថ្ងៃ ទៅនឹងសកម្មភាពប្រចាំថ្ងៃក្នុងស្ថាប័នរបស់ខ្លួន) ។

### ៣.១.៣ លទ្ធផលទទួលបាន

ក្រសួងផែនការ បានបោះមួយជំហានទៅមុខ ក្នុងការផ្តល់គោលគំនិតទស្សនៈនៃការវិភាគយេនឌ័រ និង ជំនាញយេនឌ័រក្នុងផែនការ ក៏ដូចជា ការផ្តួចផ្តើមបង្កើតស្ថិតិយេនឌ័រ ទៅឱ្យមន្ត្រីផែនការ ដែលជាជំនាញមូលដ្ឋានមួយសម្រាប់មន្ត្រីផែនការ ។ តាមរយៈសកម្មភាពទាំងនេះ អាច :

- ឆ្លើយតបទៅនឹងស្មារតីនៃការបញ្ជ្រាបយេនឌ័រដែលបានចែងនៅក្នុង *ផយអជ ២០០៦-២០១០*
- ឆ្លើយតបទៅនឹងការអនុវត្ត *ផយផក ២០០៨-២០១០*
- ឆ្លើយតបទៅនឹងការអនុវត្ត *ផែនការយុទ្ធសាស្ត្រនិងសកម្មភាពបញ្ជ្រាបយេនឌ័រក្រសួងផែនការ ២០០៨-២០១០*
- ឆ្លើយតបទៅនឹងសំណូមពររបស់ក្រសួងកិច្ចការនារី ក្នុងការជំរុញសមភាពយេនឌ័រនៅគ្រប់ក្រសួង ស្ថាប័ន ។

## ៣.២ សកម្មភាពបញ្ជ្រាបយេនឌ័រក្នុងក្រសួងផែនការ ឆ្នាំ២០០៩

ដោយមានជំនួយបច្ចេកទេស ពីមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន ដែលបានផ្តល់នូវទីប្រឹក្សាយេនឌ័រម្នាក់ ក្រសួងផែនការតាមរយៈក្រុមការងារយេនឌ័រ បានស្វែងយល់ ពី ដំណើការតាមដានត្រួតពិនិត្យនិងវាយតម្លៃផែនការ នៅតាម អង្គការ ស្ថាប័ននានា នៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ ដើម្បីរៀបចំ បញ្ជីត្រួតពិនិត្យការបញ្ជ្រាបយេនឌ័រនិងសូចនាករយេនឌ័រ ។ ការស្វែងយល់នេះ ធ្វើឡើងដោយបានជួបពិភាក្សាជាមួយ ទីប្រឹក្សានិងតំណាងក្រសួងកិច្ចការនារី ក្រុមការងារយេនឌ័រក្រសួងសុខាភិបាល និង ប្រធានអង្គការយេនឌ័រនិងការអភិវឌ្ឍព្រមទាំង លោកប្រធានមន្ទីរផែនការ និងសហការី ខេត្តកំពង់ឆ្នាំង ។ បញ្ជីត្រួតពិនិត្យការបញ្ជ្រាបយេនឌ័រ ត្រូវបានរៀបចំឡើង ហើយបណ្តុំផែនការសកម្មភាពយេនឌ័រក្រសួងផែនការ ត្រូវបានវាយតម្លៃ ។

## ៣.៣ សកម្មភាពបញ្ជ្រាបយេនឌ័រក្នុងក្រសួងផែនការ ឆ្នាំ២០១០

ក្រោមកិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ របស់មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន ក្រុមការងារយេនឌ័រក្រសួងផែនការ បាន :

- សហការជាមួយក្រសួងកិច្ចការនារី ដើម្បីរៀបចំសិក្ខាសាលា ស្តីពី ការបញ្ជ្រាបយេនឌ័រ ទៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣* កាលពីខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគារ ណាហ្គាវើល រាជធានីភ្នំពេញ។
- រៀបចំសិក្ខាសាលា ដើម្បី ការពិនិត្យឡើងវិញនូវវគ្គបណ្តុះបណ្តាលយេនឌ័រក្នុងផែនការនិងស្ថិតិ ឆ្នាំ២០០៨ និងការរៀបចំផែនការបណ្តុះបណ្តាលសម្រាប់ ឆ្នាំ២០១០ នៅខេត្តកំពត ។
- រៀបចំវគ្គបណ្តុះបណ្តាល ស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិ ដល់មន្ត្រីបង្គោលយេនឌ័រ រាជធានីខេត្ត នៅថ្ងៃទី២១-២៣ ខែមេសា ឆ្នាំ២០១០ នៅខេត្តសៀមរាប។
- ធ្វើបច្ចុប្បន្នភាព *ផែនការយុទ្ធសាស្ត្រនិងសកម្មភាពបញ្ជ្រាបយេនឌ័រក្រសួងផែនការ ២០០៨-២០១០* ទៅជា *ផយបយផក បច្ចុប្បន្នកម្ម ២០០៩-២០១៣* ។

សកម្មភាពផ្សេងៗទៀតដែលសមាជិកក្រុមការងារយេនឌ័របានចូលរួម

- ➢ ចូលរួមរៀបចំរបាយការណ៍ជាតិគួប លើកទី៤ និងទី៥ ស្តីពីការអនុវត្ត អនុសញ្ញា ស៊ី-ដ នៅកម្ពុជា ។
- ➢ រៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពស្ត្រីនៅក្រសួងផែនការ ជូនក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ។
- ➢ ចូលរួមជាសមាជិករបស់ក្រុមការងារបច្ចេកទេសបញ្ជ្រាបយេនឌ័ររបស់ក្រសួងកិច្ចការនារី ។
- ➢ ចូលរួមជាសមាជិក និងជាគ្រូបង្គោល ក្នុងសិក្ខាសាលាស្តីពី "*ឧបករណ៍ នៃការធ្វើផែនការឆ្លើយតប នឹងយេនឌ័រ*" នៅថ្ងៃទី ១៥-១៦ ខែកញ្ញា ឆ្នាំ២០០៨ របស់ក្រុមការងារយេនឌ័រ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។
- ➢ ចូលរួមកំណត់សកម្មភាព ផែនការបញ្ជ្រាបយេនឌ័រ របស់គណៈកម្មាធិការជាតិទន្លេមេគង្គ ជំហានទី៣ ។
- ➢ រៀបចំពិធីទិវាអន្តរជាតិ នារី ៨ មីនា នៅក្រសួងផែនការ ជារៀងរាល់ឆ្នាំ ។
- ➢ ចូលរួមការតាំងពិព័រណ៍ឯកសារ ស្តីពីសមិទ្ធផលរបស់ក្រសួងផែនការ ដើម្បីអបអរខួបលើកទី៩៩ ទិវានារីអន្តរជាតិ ដែលរៀបចំដោយក្រសួងកិច្ចការនារី នាថ្ងៃទី០៤ ខែមីនា ២០១០ ។
- ➢ ចូលរួមកិច្ចប្រជុំ ក្រុមការងារពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស នាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ ។
- ➢ ចូលរួមកិច្ចប្រជុំផ្សេងៗដែលទាក់ទង នឹងការងារយេនឌ័រ ។

## ៣.៤ ស្ថានភាពយេនឌ័រក្នុងក្រសួងផែនការ

វឌ្ឍនភាពជាច្រើន ត្រូវបានធ្វើឱ្យកើតមានឡើង នៅក្នុងការផ្តល់ ឋានៈនិងតួនាទី ដល់មន្ត្រីរាជការជាស្ត្រី នៅក្នុងក្រសួងផែនការ ថ្នាក់ជាតិ និង ថ្នាក់មន្ទីរផែនការរាជធានី ខេត្ត និង ការិយាល័យផែនការស្រុក ។ ទោះជាដូចនេះក្តី គម្លាតយេនឌ័រ នៅតែមានកម្រិតខ្ពស់នៅឡើយ ដែលទាមទារឱ្យមានការលើកម្ពស់បន្ថែមទៀត ដល់ស្ត្រី រួមទាំង ការផ្តល់ឋានៈតួនាទីនិងការទទួលខុសត្រូវ ការផ្តល់ឱកាសក្នុង ការងារ ការចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលផ្សេងៗ ទាំងក្នុងនិងក្រៅប្រទេស ដើម្បីឆ្លើយតបទៅ នឹងគោលនយោបាយយេនឌ័រ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ខាងក្រោមនេះគឺជាវឌ្ឍនភាពនៃស្ថានភាពរបស់មន្ត្រីរាជការស្ត្រី ក្នុងក្រសួងផែនការ ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងផ្នែក ឋានៈតួនាទី កម្រិតវប្បធម៌ និង ការចូលរួមក្នុងវគ្គបណ្តុះបណ្តាលនិងសិក្សានៅបរទេស ។ តារាង ៣.១ ជាតួលេខស្តីពី ស្ថានភាពនៃថ្នាក់ដឹកនាំ និងមន្ត្រីរាជការជាស្ត្រី នៅក្នុងក្រសួងផែនការ ថ្នាក់ជាតិ និងសមាមាត្ររបស់ស្ត្រី ធៀបនឹង ចំនួនសរុប តាមតួនាទីនីមួយៗ ។

### តារាង ៣.១ : ចំនួនថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្នុងក្រសួងផែនការ នៅថ្នាក់ជាតិ

| តួនាទី | ២០០៨ | | | ២០០៩ | | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | ស្ត្រី (%) | សរុប | ស្ត្រី | ស្ត្រី (%) |
| ទេសរដ្ឋមន្ត្រី/រដ្ឋមន្ត្រី | ១ | ០ | ០ | ១ | ០ | ០ |
| រដ្ឋលេខាធិការ | ៧ | ០ | ០ | ៧ | ០ | ០ |
| អនុរដ្ឋលេខាធិការ | ៧ | ១ | ១៤.៣ | ៧ | ១ | ១៤.៣ |
| អគ្គនាយក | ៤ | ០ | ០ | ៤ | ០ | ០.០ |
| អគ្គនាយករង | ១២ | ៤ | ៣៣.៣ | ២៩ | ៥ | ១៧.២ |
| ប្រធាននាយកដ្ឋាន/ថ្នាក់ស្មើ | ១៩ | ២ | ១០.៥ | ២៤ | ៤ | ១៦.៧ |
| អនុប្រធាននាយកដ្ឋាន | ៦៩ | ១៤ | ២០.៣ | ៦៦ | ១៥ | ២២.៧ |
| ប្រធានការិយាល័យ | ៥៩ | ១៣ | ២២.០ | ៩២ | ២៣ | ២៥.០ |
| អនុប្រធានការិយាល័យ | ១៧៣ | ៤៤ | ២៥.៤ | ២៣៩ | ៧១ | ២៩.៧ |
| បុគ្គលិក | ៣៤៣ | ១១២ | ៣២.៧ | ២៧២ | ៨៦ | ៣១.៦ |
| សរុប | ៦៩៤ | ១៩០ | ២៧.៤ | ៧៤១ | ២០៥ | ២៧.៧ |

***ប្រភព:*** *នាយកដ្ឋានបុគ្គលិកក្រសួងផែនការ ឆ្នាំ២០០៨ ២០០៩ និង ២០១០*

***កំណត់សម្គាល់:*** *បុគ្គលិករួមមានទាំងបុគ្គលិកទូទៅនិងបុគ្គលិកគាំទ្រ*

### តារាង ៣.២ : ចំនួនមន្ត្រីរាជការក្នុងក្រសួងផែនការ នៅថ្នាក់មន្ទីរផែនការរាជធានី ខេត្ត និងការិយាល័យផែនការស្រុក

| តួនាទី | ២០០៨ | | | ២០០៩ | | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | ស្ត្រី (%) | សរុប | ស្ត្រី | ស្ត្រី (%) |
| ប្រធានមន្ទីរផែនការរាជធានី-ខេត្ត | ២៤ | ២ | ៨.៣ | ២៤ | ៣ | ១២.៥ |
| អនុប្រធានមន្ទីរផែនការរាជធានី-ខេត្ត | ៦៩ | ៤ | ៥.៨ | ៨៧ | ៧ | ៨.០ |
| ប្រធានការិយាល័យផែនការរាជធានី-ខេត្ត | ៩៣ | ១៤ | ១៥.១ | ១០៦ | ១៣ | ១២.៣ |
| អនុប្រធានការិយាល័យផែនការរាជធានី-ខេត្ត | ១៦០ | ៣៩ | ២៤.៤ | ១៧៧ | ៥៣ | ២៩.៩ |
| ប្រធានការិយាល័យផែនការក្រុង-ស្រុក-ខណ្ឌ | ១១១ | ៩ | ៨.១ | ១១៦ | ១១ | ៩.៥ |
| អនុប្រធានការិយាល័យផែនការក្រុង-ស្រុក-ខណ្ឌ | ១១៩ | ១៦ | ១៣.៤ | ១១៣ | ១៨ | ១៥.៩ |
| បុគ្គលិក | ៣៨៦ | ១១៨ | ៣០.៦ | ៣១០ | ៩៤ | ៣០.៣ |
| សរុប | ៩៦២ | ២០២ | ២១.០ | ៩៣៣ | ១៩៩ | ២១.៣ |

***ប្រភព :*** *នាយកដ្ឋានបុគ្គលិកក្រសួងផែនការ ឆ្នាំ២០០៩*

តារាង ៣.២ បង្ហាញពីស្ថានភាពមន្ត្រី រាជការស្ត្រីក្នុងក្រសួងផែនការនៅថ្នាក់មន្ទីរផែនការខេត្ត និង ការិយាល័យស្រុក និងសមាមាត្រស្ត្រី ធៀបនឹងចំនួន សរុប តាមតួនាទី និងកម្រិតនីមួយៗ ។ តារាង ៣.៣ បង្ហាញពីស្ថានភាពនៃកម្រិតអប់រំរបស់មន្ត្រីរាជការស្ត្រី នៅក្រសួងផែនការ នៅថ្នាក់ជាតិ ហើយតារាងចុងក្រោយ (តារាង ៣.៤) បង្ហាញពីស្ថានភាពរបស់មន្ត្រីរាជការ (ជាពិសេស មន្ត្រីរាជញការជាស្ត្រី) ក្នុងក្រសួងផែនការ ដែលបានចូលរួមការបណ្តុះបណ្តាលនៅបរទេស ។

## តារាង ៣.៣ : កម្រិតអប់រំមន្ត្រីរាជការក្នុងក្រសួងផែនការ នៅថ្នាក់ជាតិ

| កម្រិតអប់រំ | ២០០៨ | | | ២០០៩ | | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | ស្ត្រី (%) | សរុប | ស្ត្រី | ស្ត្រី (%) |
| បណ្ឌិត | ១ | ០ | ០ | ១ | ០ | ០ |
| បរិញ្ញាបត្រជាន់ខ្ពស់ | ៣៧ | ៦ | ១៦.២ | ៤៣ | ៨ | ១៨.៦ |
| បរិញ្ញាបត្រ | ៣២៥ | ៦៥ | ២០.០ | ៤២៤ | ១០៣ | ២៤.៣ |
| មធ្យមសិក្សាបច្ចេកទេស | ១៤៨ | ៤៣ | ២៩.១ | ២២០ | ៧៦ | ៣៤.៥ |
| កម្មករជំនាញ | ៣៦ | ១៥ | ៤១.៧ | ១ | ០ | ០ |
| ចំណេះទូទៅ ឬមធ្យមសិក្សា | ៣៣ | ១២ | ៣៦.៤ | ៣១ | ១៣ | ៤១.៩ |
| សរុប | ៥៨០ | ១៤១ | ២៤.៣ | ៧២០ | ២០០ | ២៧.៨ |

***ប្រភព*** *: នាយកដ្ឋានបុគ្គលិកក្រសួងផែនការ ឆ្នាំ២០០៩*

***កំណត់សម្គាល់*** *: - ជំនាញបច្ចេកទេសមធ្យម = កម្រិតអប់រំថ្នាក់ទី១២ បូកការបណ្តុះបណ្តាលបច្ចេកទេសមធ្យម ២-៣ឆ្នាំ*

*- ជំនាញបច្ចេកទេសបឋម = កម្រិតអប់រំថ្នាក់ទី៩ បូកការបណ្តុះបណ្តាលវិជ្ជាជីវៈ ២-៣ឆ្នាំ*

*- ការអប់រំទូទៅ= កម្រិតអប់រំថ្នាក់ទី១២ ឬ តិចជាង*

## តារាង ៣.៤ : ចំនួនមន្ត្រីរាជការក្នុងក្រសួងផែនការ ដែលបានទទួលការបណ្តុះបណ្តាលនៅបរទេស

| រយៈពេលបណ្តុះបណ្តាល | ២០០៨ | | | ២០០៩ | | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | ស្ត្រី (%) | សរុប | ស្ត្រី | ស្ត្រី (%) |
| ០១-១០ ថ្ងៃ | ៩៧ | ១០ | ១០.៣ | ៩៨ | ៧ | ៧.១ |
| ១១-៥៤ ថ្ងៃ | ១៩ | ៤ | ២១.១ | ២០ | ២ | ១០.០ |
| ២ ឆ្នាំ | ៣ | ០ | ០ | ០ | ០ | ០ |
| សរុប | ១១៩ | ១៤ | ១១.៨ | ១១៨ | ៩ | ៧.៦ |

***ប្រភព*** *: នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ និង នាយកដ្ឋានបុគ្គលិក ក្រសួងផែនការ ឆ្នាំ២០០៩*

# ជំពូកទី៤

# គោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពបញ្ជ្រាបយេនឌ័រ ក្នុងក្រសួងផែនការ ២០០៩-២០១៣

## ៤.១ គោលនយោបាយ

គោលនយោបាយយេនឌ័ររបស់ក្រសួងផែនការ មានដូចខាងក្រោម :

១. បន្តខិតខំប្រឹងប្រែងបញ្ជ្រាបការងារយេនឌ័រ ទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ កម្មវិធី និងគម្រោងនានា ។

២. បន្តពង្រឹងសមត្ថភាពមន្ត្រីរាជការក្រសួងផែនការទាំងស្ត្រីនិងបុរស ក្នុងការឆ្លើយតបនឹងតម្រូវការយេនឌ័រ ការបង្កើតសូចនាករយេនឌ័រ ចំណេះដឹងស្ថិតិ ផែនការ និងការវិភាគយេនឌ័រ ការបង្កើតស្ថិតិយេនឌ័រ ការវិភាគយេនឌ័រក្នុងផែនការ ការវាយតម្លៃស្ថានភាពយេនឌ័រក្នុងផែនការ ការតាមដាននិងត្រួតពិនិត្យការឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ និង ជំនាញគ្រប់គ្រង តាមរយៈ ការបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា ទាំងក្នុងនិងក្រៅប្រទេស និង មធ្យោបាយផ្សេងៗទៀត ។

៣. បង្កើនការគ្រប់គ្រងធនធានមនុស្សក្នុងក្រសួងផែនការ ក្នុងការជ្រើសរើស តែងតាំងនិងតម្លើងឋានៈតួនាទី និង ផ្តល់ឱកាស ដល់ស្ត្រីនិងបុរស ឱ្យមាន សមភាព និងសមធម៌ ។

## ៤.២ យុទ្ធសាស្ត្រ

ការបញ្ជ្រាបយេនឌ័រ គឺជាស៊េរីនៃយុទ្ធសាស្ត្រនិងដំណើរការ សម្រាប់ធ្វើការផ្លាស់ប្តូរវិធីសាស្ត្រក្នុងការដឹកនាំគ្រប់គ្រងស្ថាប័ន និងតួនាទីរបស់សមាជិកខ្លួន សំដៅសម្រេចបានសមភាពយេនឌ័រ ។ ជាមួយការយល់ដឹងនេះ និងជាមួយនឹងយុទ្ធសាស្ត្ររបស់ក្រសួងផែនការសម្រាប់ធ្វើឱ្យសម្រេចការបញ្ជ្រាបយេនឌ័រក្នុងក្រសួងផែនការ ក្រុមការងារយេនឌ័រក្រសួងផែនការ នឹងធ្វើការជាមួយក្រុមគោលដៅចំនួន ៣ នៃក្រសួងផែនការ គឺ (១) មន្ត្រីជាន់ខ្ពស់និងថ្នាក់ដឹកនាំក្រសួងផែនការ (២) មន្ត្រីរាជការក្រសួងផែនការថ្នាក់ជាតិ និង (៣)មន្ត្រីរាជការក្រសួងផែនការថ្នាក់ក្រោមជាតិ ។

ក្រុមការងារយេនឌ័រក្រសួងផែនការ នឹងប្រើប្រាស់យុទ្ធសាស្ត្រដូចខាងក្រោម ដើម្បីធ្វើការជាមួយក្រុមគោលដៅទាំង ៣ នេះ :

### (១) មន្ត្រីជាន់ខ្ពស់និងថ្នាក់ដឹកនាំក្រសួងផែនការ

*យុទ្ធសាស្ត្រ ១.១ :* បន្តលើកសំណើដល់ថ្នាក់ដឹកនាំ ដើម្បីជំរុញឱ្យមានការតម្លើងឋានៈ តួនាទីស្ត្រី ទៅក្នុងលំដាប់ថ្នាក់ ជាអ្នកគ្រប់គ្រងនិងដឹកនាំ ក្នុងក្រសួងផែនការ ។

*យុទ្ធសាស្ត្រ ១.២ :* បន្តលើកសំណើដល់ថ្នាក់ដឹកនាំ ក្នុងការផ្តល់អាទិភាពខ្ពស់ ដល់ការងារយេនឌ័រ នៅក្នុងដំណើរការរៀបចំ ផែនការ និងការវិភាគគោលនយោបាយ ។

*យុទ្ធសាស្ត្រ ១.៣ :* បន្តលើកសំណើដល់ថ្នាក់ដឹកនាំ ក្នុងការគាំទ្រ ដល់ក្រុមការងារយេនឌ័រក្រសួងផែនការ រួមទាំង ការវិភាជន៍ថវិកាជាតិ ដើម្បីអនុវត្ត *ផយបយផក បច្ចុប្បន្នកម្ម* ។

(២) មន្ត្រីរាជការក្រសួងផែនការថ្នាក់ជាតិ

*យុទ្ធសាស្ត្រ ២.១ :* បណ្តុះបណ្តាលមន្ត្រីរាជការក្រសួងផែនការ ដើម្បីបង្កើនសមត្ថភាព ស្តីពី ការរៀបចំផែនការ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ស្ថិតិ និង ការវិភាគគោលនយោបាយ ដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ ។

*យុទ្ធសាស្ត្រ ២.២ :* ជំរុញនិងលើកកម្ពស់ ការរៀបចំផែនការ ការងារស្ថិតិ និង ការតាមដានត្រួតពិនិត្យវាយតម្លៃ ដោយផ្តើមចេញពីទស្សនៈយេនឌ័រ ។

*យុទ្ធសាស្ត្រ ២.៣ :* ជំរុញនិងលើកទឹកចិត្ត ដល់ស្ត្រី ក្នុងការបង្កើនសមត្ថភាព ដើម្បីឆ្លើយតបនឹងតម្រូវការការងារ តួនាទី និង ឋានៈរបស់ខ្លួន ។

(៣) មន្ត្រីរាជការក្រសួងផែនការថ្នាក់ក្រោមជាតិ

*យុទ្ធសាស្ត្រ ៣.១ :* បណ្តុះបណ្តាលមន្ត្រីរាជការថ្នាក់ក្រោមជាតិ ដើម្បីបង្កើនសមត្ថភាព ស្តីពី ការរៀបចំផែនការ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ស្ថិតិ និង ការវិភាគគោលនយោបាយ ដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ ។

*យុទ្ធសាស្ត្រ ៣.២ :* ជំរុញនិងលើកកម្ពស់ ការរៀបចំផែនការ ការងារស្ថិតិ និង ការតាមដានត្រួតពិនិត្យវាយតម្លៃ ដោយផ្តើមចេញពីទស្សនៈយេនឌ័រ ។

*យុទ្ធសាស្ត្រ ៣.៣ :* ជំរុញនិងលើកទឹកចិត្ត ដល់ស្ត្រី ក្នុងការបង្កើនសមត្ថភាព ដើម្បីឆ្លើយតបនឹងតម្រូវការការងារ តួនាទី និង ឋានៈរបស់ខ្លួន ។

ក្រៅពីបណ្តាយុទ្ធសាស្ត្រខាងលើ ក្រុមការងារយេនឌ័រក្រសួងផែនការ ត្រូវបានប្រគល់តួនាទីឱ្យធ្វើការ ជាមួយភ្នាក់ងារគាំទ្រផ្សេងៗទៀត ជាពិសេស ក្រសួងកិច្ចការនារី ដើម្បីជំរុញការបញ្ជ្រាបយេនឌ័រក្នុងក្រសួងផែនការ ។

## ៤.៣ សកម្មភាព

បណ្តាសកម្មភាពខាងក្រោម នឹងត្រូវបានសម្របសម្រួលនិងអនុវត្ត ដោយក្រុមការងារយេនឌ័រក្រសួងផែនការ ដោយមានការគាំទ្រពីថ្នាក់ដឹកនាំនៃក្រសួងផែនការ និងដោយមានកិច្ចសហការពីដៃគូអភិវឌ្ឍន៍ និងអ្នកដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត ។ សំណើសកម្មភាពជាក់លាក់នានា ទៅតាមយុទ្ធសាស្ត្រនីមួយៗ ដែលបានកំណត់ខាងលើ មានបង្ហាញក្នុងតារាង ៤.១ ខាងក្រោម :

## តារាង ៤.១ : ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្រសួងផែនការ

| យុទ្ធសាស្ត្រ | សកម្មភាព | ពេលវេលា | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | |
| **១. យុទ្ធសាស្ត្រនិងសកម្មភាព ដែលផ្ដោតលើ មន្ត្រីជាន់ខ្ពស់និងថ្នាក់ដឹកនាំក្រសួងផែនការ** | | | | | | | |
| ១.១ បន្តលើកសំណើដល់ថ្នាក់ដឹកនាំ ដើម្បីជំរុញឱ្យមានការតម្លើងឋានៈ តួនាទីស្ត្រី ទៅក្នុង លំដាប់ថ្នាក់ ជាអ្នកគ្រប់គ្រងនិងដឹកនាំក្នុង ក្រសួងផែនការ | ធ្វើតារាងមន្ត្រីរាជការស្ត្រីដែលបានបណ្ដុះបណ្ដាល និងមានបទពិសោធន៍ដើម្បីពិនិត្យស្នើឡើង នូវឋានៈនិងតួនាទី | | | ✓ | ✓ | ✓ | |
| | បែងចែកភារៈកិច្ចសំខាន់ៗ ដល់មន្ត្រីរាជការជាស្ត្រី ដើម្បីបង្ហាញ ពីសមត្ថភាព | ✓ | ✓ | ✓ | ✓ | ✓ | |
| | ត្រួតពិនិត្យវឌ្ឍនភាពក្នុងការតម្លើងឋានៈដល់មន្ត្រីរាជការជាស្ត្រី | ✓ | ✓ | ✓ | ✓ | ✓ | |
| | សំណូមពរទៅថ្នាក់ដឹកនាំ ដើម្បីបញ្ចូលតំណាងក្រុមការងារបញ្ជ្រាបយេនឌ័រ ទៅក្នុងក្រុមការងារបច្ចេកទេស នានារបស់ក្រសួងផែនការ | ✓ | ✓ | ✓ | ✓ | ✓ | |
| ១.២ បន្តលើកសំណើដល់ថ្នាក់ដឹកនាំ ក្នុងការផ្ដល់អាទិភាពខ្ពស់ដល់ការងារយេនឌ័រ នៅក្នុងដំណើរការរៀបចំផែនការ និងការវិភាគគោលនយោបាយ ។ | បើកវេទិកាពិភាក្សាលើប្រធានបទស្ដីពីការបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិ ដើម្បីស្វែងរកការគាំទ្រពីថ្នាក់ដឹកនាំ | | | ✓ | ✓ | ✓ | |
| | វាយតម្លៃតម្រូវការសម្រាប់ការបណ្ដុះបណ្ដាលលើការរៀបចំផែនការ ស្ថិតិ និងវិភាគគោលនយោបាយក្នុងក្រសួងផែនការ និងរាយការណ៍លទ្ធផលទៅថ្នាក់ដឹកនាំក្រសួង | | | ✓ | ✓ | ✓ | |
| | អញ្ជើញថ្នាក់ដឹកនាំជាន់ខ្ពស់ទៅចូលរួមរាល់ការប្រជុំក្រុមការងារបញ្ជ្រាបយេនឌ័រ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ផ្ដល់របាយការណ៍ជាប្រចាំ ស្ដីពីលទ្ធផល នៃសកម្មភាពក្រុមការងារបញ្ជ្រាបយេនឌ័រ និងវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រដល់ថ្នាក់ដឹកនាំ | ✓ | ✓ | ✓ | ✓ | ✓ | |
| | បើកវេទិកាកម្រិតខ្ពស់និងសិក្ខាសាលាសម្រាប់អ្នកវិភាគគោលនយោបាយ ក្នុងក្រសួង-ផែនការ ស្ដីពីការវិភាគគោលនយោបាយ ផ្ដើមចេញពីទស្សនយេនឌ័រ | | | ✓ | ✓ | ✓ | |

| យុទ្ធសាស្ត្រ | សកម្មភាព | ពេលវេលា | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | |
| | បញ្ចូលសារៈសំខាន់នៃសមភាពយេនឌ័រនិងបញ្ហាយេនឌ័រ ទៅក្នុងសុន្ទរកថា ផ្លូវការ ក្នុងកិច្ចប្រជុំជាសាធារណៈដែលអាចធ្វើទៅបាន | ✓ | ✓ | ✓ | ✓ | ✓ | |
| ១.៣ បន្តលើកសំណើដល់ថ្នាក់ដឹកនាំក្នុងការគាំទ្រ ដល់ក្រុមការងារយេនឌ័រក្រសួងផែនការ រួម ទាំងការវិភាគជន៍ថវិកាជាតិ ដើម្បីអនុវត្តផែនការយេនឌ័រ បច្ចុប្បន្នកម្ម | រៀបចំផែនការប្រតិបត្តិយេនឌ័រប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | |
| | បញ្ជូនផែនការសកម្មភាពប្រតិបត្តិ និងគម្រោងថវិកាយេនឌ័រ ទៅថ្នាក់ដឹកនាំជាន់ខ្ពស់ ដើម្បីពិនិត្យ និងសម្រេច | ✓ | ✓ | ✓ | ✓ | ✓ | |
| | ផ្តល់ដល់ក្រុមការងារយេនឌ័រ នូវការឧបត្ថម្ភជាកម្រៃ និងការគាំទ្រជាសំភារៈ ឬហិរញ្ញវត្ថុ ដើម្បីឱ្យក្រុមការងារអាចបន្តភារកិច្ចខ្លួនបាន | | ✓ | ✓ | ✓ | ✓ | |
| | ធ្វើការតស៊ូមតិដើម្បីឱ្យថ្នាក់ដឹកនាំវិភាជន៍ថវិកា សម្រាប់អនុវត្តផែនការប្រតិបត្តិយេនឌ័រប្រចាំឆ្នាំ រួមទាំង ការរៀបចំទិវាអន្តរជាតិនារី ៨មីនា ក្នុងករណីថវិកាវិភាជន៍មិនគ្រប់គ្រាន់តាមសំណើ | | ✓ | ✓ | ✓ | ✓ | |
| **២. យុទ្ធសាស្ត្រនិងសកម្មភាព ដែលផ្តោតលើ មន្ត្រីរាជការក្រសួងផែនការថ្នាក់ជាតិ** | | | | | | | |
| ២.១ បណ្តុះបណ្តាលមន្ត្រីរាជការក្រសួងផែនការ ដើម្បីបង្កើនសមត្ថភាព ស្តីពី ការរៀបចំផែនការ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃស្ថិតិ និង ការវិភាគគោលនយោបាយ ដែលឆ្លើយតបទៅនឹង តម្រូវការយេនឌ័រ | តាមដានត្រួតពិនិត្យនិងវាយតម្លៃ ការបណ្តុះបណ្តាល តាមរយៈ ការប្រជុំជាប្រចាំ ការរាយការណ៍ និង ពិគ្រោះយោបល់ ។ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ប្រើប្រាស់លទ្ធផលនៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាល និងលើកសំណើសម្រាប់អាទិភាព ដើម្បីផ្តល់ដល់មន្ត្រីរាជការជាស្ត្រីសម្រាប់ការបង្កើនសមត្ថភាព | | ✓ | ✓ | ✓ | ✓ | |
| | រៀបចំ ឯកសារនិងសម្ភារ សម្រាប់ការបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំពិគ្រោះយោបល់ នានា | | | ✓ | ✓ | ✓ | |
| | លើកសំណើសុំជំនួយបច្ចេកទេស សម្រាប់ដំណើរការការងារយេនឌ័រ | | | ✓ | ✓ | ✓ | |
| | រៀបចំបណ្តុះបណ្តាលកម្រិតខ្ពស់និងសិក្ខាសាលា សម្រាប់អ្នកវិភាគគោលនយោបាយ ក្នុងក្រសួង ផែនការ ស្តីពី ការវិភាគគោលនយោបាយ ផ្តើមចេញពីទស្សនៈយេនឌ័រ | | | ✓ | ✓ | ✓ | |

| យុទ្ធសាស្ត្រ | សកម្មភាព | ពេលវេលា | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | |
| | រៀបចំការបណ្តុះបណ្តាលស្តីពីការតាមដានត្រួតពិនិត្យនិងវាយតំលៃ ពីការបញ្ជ្រាបយេនឌ័រក្នុង ផែនការនិងស្ថិតិ | ✓ | ✓ | ✓ | ✓ | ✓ | |
| | រៀបចំការបណ្តុះបណ្តាលស្តីពីការប្រមូលនិងចងក្រងទិន្នន័យស្ថិតិយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ ក្នុងផែនការ និងស្ថិតិ | ✓ | ✓ | ✓ | ✓ | ✓ | |
| | រៀបចំការបណ្តុះបណ្តាលស្តីពីការវិភាគ និងប្រើប្រាស់ ស្ថិតិយេនឌ័រទៅក្នុងផែនការ | ✓ | ✓ | ✓ | ✓ | ✓ | |
| | រៀបចំការបណ្តុះបណ្តាលស្តីពីការវិភាគស្ថិតិយេនឌ័រ ស៊ីជម្រៅ និងសន្ទស្សន៍ ការអភិវឌ្ឍន៍មនុស្ស | | | ✓ | ✓ | ✓ | |
| | រៀបចំឱ្យមានទស្សនកិច្ចសិក្សាអំពីការងារយេនឌ័រក្នុងផែនការស្ថិតិ នៅក្នុងនិងក្រៅប្រទេស | | | ✓ | ✓ | ✓ | |
| **២.២** ជំរុញនិងលើកកម្ពស់ ការរៀបចំផែនការ ការងារស្ថិតិ និង ការតាមដានត្រួតពិនិត្យវាយតម្លៃ ដោយផ្តើមចេញពីទស្សនៈយេនឌ័រ | រៀបចំនិងបង្កើត សូចនាករយេនឌ័រក្នុង ផែនការនិងស្ថិតិ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ពិនិត្យឡើងវិញនិងធ្វើឱ្យប្រសើរឡើងកម្រងសំណួរជំរឿន និងអង្កេតនានា និងអំពីវិធីសាស្ត្រ ដែលត្រូវប្រមូលទិន្នន័យ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ពិនិត្យឡើងវិញនិងធ្វើឱ្យប្រសើរឡើងការបំបែកទិន្នន័យតាមយេនឌ័រ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ផ្តួចផ្តើមគំនិតនិងលើកសំណើ ស្តីពីការបញ្ជ្រាបយេនឌ័រ ទៅក្នុងរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិឆ្នាំ២០១១ នៃការ អនុវត្ត *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* | | | ✓ | | | |
| | ផ្តួចផ្តើមគំនិតនិងលើកសំណើ ស្តីពីការបញ្ជ្រាបយេនឌ័រ ទៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការអនុវត្ត *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* | | | | ✓ | | |
| | លើកសំណើ ស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុង *ផយអជ ២០១៤ ២០១៨* | | | | | ✓ | |
| | រៀបចំប្រជុំ ប្រចាំ ឆមាស-ឆ្នាំ ដើម្បីត្រួត ពិនិត្យការងារយេនឌ័រ និងការតាមដានត្រួតពិនិត្យ | ✓ | ✓ | ✓ | ✓ | ✓ | |

| យុទ្ធសាស្ត្រ | សកម្មភាព | ពេលវេលា | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | |
| **២.៣** ជំរុញនិងលើកទឹកចិត្តដល់ស្ត្រី ក្នុងការបង្កើនសមត្ថភាព ដើម្បី ឆ្លើយតបនឹងតម្រូវការ ការងារ តួនាទី និងឋានៈរបស់ខ្លួន | បន្តលើកសំណើទៅថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ដើម្បីលើកទឹកចិត្តបញ្ជូនមន្ត្រីរាជការជាស្ត្រីទៅបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស | ✓ | | ✓ | ✓ | ✓ | |
| | បញ្ជូនមន្ត្រីរាជការជាស្ត្រីទៅបណ្តុះបណ្តាលបច្ចេកទេស ( ស្ថិតិ ផែនការ ការតាមដានត្រួតពិនិត្យវាយតម្លៃ និងការវិភាគគោលនយោបាយ | | | ✓ | ✓ | ✓ | |
| | រៀបចំការបណ្តុះបណ្តាល ស្តីពី ការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ដោយផ្តល់អាទិភាពឱ្យបានច្រើនចំពោះមន្ត្រីរាជការជាស្ត្រី | | | ✓ | ✓ | ✓ | |
| | លើកសំណូមពរទៅមន្ត្រីគ្រប់គ្រងជាន់ខ្ពស់ ឱ្យបែងចែកការងារបច្ចេកទេស ឬ ការងារគ្រប់គ្រង ទៅឱ្យមន្ត្រីរាជការជាស្ត្រី ដើម្បីអាចឱ្យគេបង្ហាញពីប្រសិទ្ធភាព និងការប្តេជ្ញា ចិត្តដើម្បីពង្រឹងសមត្ថភាពរបស់គេ | ✓ | ✓ | ✓ | ✓ | ✓ | |
| | រៀបចំឱ្យមានទស្សនកិច្ចសិក្សាស្តីពីការងារយេនឌ័រក្នុងផែនការនិងស្ថិតិ ក្នុងនិងក្រៅប្រទេស ដោយផ្តល់អាទិភាពខ្ពស់ ដល់មន្ត្រីរាជការជាស្ត្រី | ✓ | ✓ | ✓ | ✓ | ✓ | |
| **៣. យុទ្ធសាស្ត្រនិងសកម្មភាព ដែលផ្តោតលើ មន្ត្រីរាជការក្រសួងផែនការថ្នាក់ក្រោមជាតិ** | | | | | | | |
| **៣.១** បណ្តុះបណ្តាលមន្ត្រីរាជការថ្នាក់ក្រោមជាតិ ដើម្បីបង្កើនសមត្ថភាព ស្តីពី ការរៀបចំផែនការ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ស្ថិតិ និង ការវិភាគគោលនយោបាយ ដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ | សិក្សាវាយតម្លៃពីតម្រូវការវគ្គបណ្តុះបណ្តាលពីការងារយេនឌ័រ នៅថ្នាក់ក្រោមជាតិ | | | ✓ | | | |
| | រៀបចំការបណ្តុះបណ្តាលពី ការវិភាគយេនឌ័រ ការរៀបចំផែនការឆ្លើយតបទៅនឹងតម្រូវការ យេនឌ័រ និង ការតាមដានត្រួតពិនិត្យវាយតម្លៃយេនឌ័រ ក៏ដូចជា ស្ថិតិយេនឌ័រ ដល់មន្ត្រីរាជការ នៅមន្ទីរផែនការថ្នាក់រាជធានី-ខេត្ត | | | ✓ | ✓ | ✓ | |
| | មន្ត្រីផែនការត្រូវទទួលខុសត្រូវ ក្នុងការសម្រួលការបញ្ចូលការងារយេនឌ័រក្នុងផែនការរាជធានី-ខេត្ត ឬ ក្រុង-ស្រុក-ខណ្ឌ ក៏ដូចជាផែនការ ថ្នាក់ មូលដ្ឋាន និង ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ | ✓ | ✓ | ✓ | ✓ | ✓ | |

| យុទ្ធសាស្ត្រ | សកម្មភាព | ពេលវេលា | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | |
| | រៀបចំការបណ្តុះបណ្តាល លើប្រធានបទ ការបញ្ជ្រាប យេនឌ័រ ក្នុងផែនការ និងស្ថិតិ ដល់មន្ត្រីបង្គោលយេនឌ័រ ផែនការរាជធានី-ខេត្ត | ✓ | ✓ | | | | |
| | បើកវគ្គបណ្តុះបណ្តាលបន្តដល់មន្ត្រី ផែនការ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | | ✓ | ✓ | ✓ | ✓ | |
| | ណែនាំផ្សព្វផ្សាយអំពីការប្រើប្រាស់ សូចនាករយេនឌ័រក្នុងប្រព័ន្ធស្ថិតិ ផែនការ | ✓ | ✓ | ✓ | ✓ | ✓ | |
| | រៀបចំការបណ្តុះបណ្តាលដោយផ្តោតលើមន្ត្រីរាជការជាស្ត្រី នៅថ្នាក់ក្រោមជាតិ ពី ស្ថិតិមូលដ្ឋាន ផែនការនិងការតាមដានត្រួតពិនិត្យវាយតម្លៃ និង ការវិភាគគោល នយោបាយ | | | ✓ | ✓ | ✓ | |
| ៣.២ ជំរុញនិងលើកកម្ពស់ ការរៀបចំផែនការ ការងារស្ថិតិ និងការតាមដានត្រួតពិនិត្យវាយតម្លៃ ដោយផ្តើមចេញពីទស្សនៈយេនឌ័រ | ផ្តល់អនុសាសន៍ដល់ឧត្តមមន្ត្រីជាន់ខ្ពស់ថ្នាក់ខេត្ត ដើម្បីផ្តល់ឱកាស ដល់មន្ត្រី រាជការជាស្ត្រីចូលរួមការរៀបចំបណ្តុះបណ្តាល នៅក្នុង និងក្រៅខេត្ត | ✓ | ✓ | ✓ | ✓ | ✓ | |
| | រៀបចំសិក្ខាសាលាថ្នាក់ក្រោមជាតិស្តីពីការបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិ | ✓ | ✓ | ✓ | ✓ | ✓ | |
| | រៀបចំនិងផ្តល់តារាងត្រួតពិនិត្យ សម្រាប់មន្ត្រីរាជការនៅមន្ទីរផែនការខេត្ត ដើម្បីប្រើ-ប្រាស់ ជាការណែនាំមួយសម្រាប់ការតាមដានត្រួតពិនិត្យការឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ ក្នុងការរៀបចំផែនការថ្នាក់មូលដ្ឋាន និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ | | | ✓ | ✓ | ✓ | |
| | ផ្តួចផ្តើមគំនិតនិងលើកសំណើ ស្តីពីការបញ្ជ្រាបយេនឌ័រ ទៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ នៃការអនុវត្ត *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រាជធានី ខេត្ត* | | | ✓ | ✓ | ✓ | |
| | ផ្តួចផ្តើមគំនិតនិងលើកសំណើ ស្តីពីការបញ្ជ្រាបយេនឌ័រ ទៅក្នុងការរៀបចំ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រាជធានី ខេត្ត* | | | ✓ | ✓ | ✓ | |
| | សំណើសុំបញ្ចូលជនបង្គោលយេនឌ័រស្ត្រី នៃមន្ទីរផែនការរាជធានី ខេត្ត ទៅក្នុងក្រុមបច្ចេកទេសនានា នៅថ្នាក់ក្រោមជាតិ | | | ✓ | ✓ | ✓ | |
| | រៀបចំការប្រជុំប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យនិងផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ពីការធ្វើការវិភាគយេនឌ័រ ការរៀបចំផែនការឆ្លើយតប ទៅនឹងតម្រូវការយេនឌ័រ ការតាមដានត្រួតពិនិត្យវាយតម្លៃយេនឌ័រ និង ស្ថិតិយេនឌ័រ | ✓ | ✓ | ✓ | ✓ | ✓ | |

| យុទ្ធសាស្ត្រ | សកម្មភាព | ពេលវេលា | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | |
| **៣.៣** ជំរុញនិងលើកទឹកចិត្ត ដល់ ស្ត្រី ក្នុងការបង្កើនសមត្ថភាព ដើម្បីឆ្លើយតបនឹងតម្រូវការ ការងារ តួនាទី និង ឋានៈរបស់ខ្លួន | រៀបចំការបណ្តុះបណ្តាលដល់មន្ត្រីគ្រប់គ្រងជាន់ខ្ពស់នៅមន្ទីរផែនការថ្នាក់ក្រោមជាតិ ដើម្បីបង្កើតបរិយាកាសសម្រាប់ការចូលរួមរបស់ស្ត្រីក្នុងការងារ និងការធ្វើសេចក្តីសម្រេចចិត្តក្នុងអង្គភាព និងដើម្បីអាចតម្លើងឋានៈ | | | ✓ | ✓ | ✓ | |
| | ត្រួតពិនិត្យវឌ្ឍនភាពនៃការជ្រើសរើស និងតម្លើងឋានៈ ដល់មន្ត្រីរាជការ នៅថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ✓ | |
| | រៀបចំការបណ្តុះបណ្តាលបច្ចេកទេសពី ការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ដោយផ្តល់អាទិភាពឱ្យបានច្រើនចំពោះមន្ត្រីរាជការជាស្ត្រី នៅថ្នាក់ក្រោមជាតិ | | | ✓ | ✓ | ✓ | |
| | បញ្ជូនមន្ត្រីរាជការជាស្ត្រីនៅថ្នាក់ក្រោមជាតិទៅបណ្តុះបណ្តាលបច្ចេកទេស ( ស្ថិតិ ផែនការ ការតាមដានត្រួត ពិនិត្យវាយតម្លៃ និងការវិភាគគោលនយោបាយ) | | | ✓ | ✓ | ✓ | |
| | រៀបចំសិក្ខាសាលានិងការបណ្តុះបណ្តាល ផ្សេងៗ ទាក់ទងនឹងបំបាត់ ការរើសអើងចំពោះ ស្ត្រីភេទ និង ស៊ុ-ដ ដើម្បីបង្កើនការយល់ដឹងពីយេនឌ័រ ក្នុង ចំណោមមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ✓ | |
| | រាយការណ៍ករណីពីការរើសអើងចំពោះស្ត្រីភេទក្នុងអង្គប្រជុំ ឬបង្កើតក្រុមសារទុក្ខក្នុងមន្ទីរផែនការរាជធានី-ខេត្ត | | | ✓ | ✓ | ✓ | |
| | ដឹកនាំវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ ដល់មន្ត្រីផែនការជាន់ខ្ពស់ថ្នាក់ក្រោម ជាតិ ដើម្បីឱ្យយល់ដឹងពីសមភាពយេនឌ័រក្នុងកន្លែងធ្វើការ (ស៊ុ-ដ) ហើយផ្តល់ការ គាំទ្រដល់ស្ត្រីនៅកន្លែងធ្វើការ និងធ្វើឱ្យមានតុល្យភាពការងារនិងកាតព្វកិច្ចគ្រួសារ | ✓ | ✓ | ✓ | ✓ | ✓ | |
| | បញ្ជូនមន្ត្រីរាជការជាស្ត្រីនៅថ្នាក់ក្រោមជាតិទៅបណ្តុះបណ្តាល ពីការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំ | | | ✓ | ✓ | ✓ | |

| យុទ្ធសាស្ត្រ | សកម្មភាព | ពេលវេលា | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | |
| **៤. យុទ្ធសាស្ត្រនិងសកម្មភាព ដែលផ្តោតលើ ការទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗ** | | | | | | | |
| ៤.១ ជំរុញដំណើរការនៃការបញ្ជ្រាបយេនឌ័រ ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយ ក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធផ្សេងទៀត និងដៃគូអភិវឌ្ឍន៍ នានា | បន្តសម្របសម្រួលនិងពិភាក្សា ជាមួយក្រសួងកិច្ចការនារី រិះរកវិធីសាស្ត្រផ្សេងៗ ដើម្បីពង្រឹងការបញ្ជ្រាបយេនឌ័រនៅក្នុងក្រសួងផែនការ | | | ✓ | ✓ | ✓ | |
| | បន្តសម្របសម្រួលនិងពិភាក្សា ជាមួយដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធនានា ដើម្បីបន្តដំណើរការនៃការបញ្ជ្រាបយេនឌ័រនៅក្នុងក្រសួងផែនការ | ✓ | ✓ | ✓ | ✓ | ✓ | |
| | បន្តបញ្ចូល កិច្ចពិភាក្សាពីយេនឌ័រ ក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសផ្សេងទៀត | ✓ | ✓ | ✓ | ✓ | ✓ | |
| | បង្កើនការប្រើប្រាស់ទិន្នន័យមូលដ្ឋាន ស្តីពីយេនឌ័រ ឱ្យបានទូលំទូលាយថែមទៀត ទាំងនៅក្នុងនិងក្រៅប្រទេស | ✓ | ✓ | ✓ | ✓ | ✓ | |
| | សម្របសម្រួលនិងកៀរគរ ដៃគូអភិវឌ្ឍន៍នានា ដើម្បីចូលរួមគាំទ្របច្ចេកទេសនិងហិរញ្ញវត្ថុ ក្នុងការអនុវត្ត *ផយបយផក បច្ចុប្បន្នកម្ម ២០០៩-២០១៣* | ✓ | ✓ | ✓ | ✓ | ✓ | |

## ឧបសម្ព័ន្ធ ១

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួង ផែនការ**

លេខ :៧៤៤ម្រ.កផក.

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០១០*

### ប្រកាស

ស្ដីពី

**ការបង្កើតក្រុមការងារយេនឌ័រក្រសួងផែនការ**

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២នស/១៩៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៧ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងឥស្សរជនចំនួន ២០៥រូប ជា អនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងផែនការ
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅ របស់ក្រសួង និងរដ្ឋលេខាធិកាដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញ អនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងកិច្ចការនារី
- បានឃើញ លិខិតរបស់ក្រសួងកិច្ចការនារីលេខ ៣៧៨ កកន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៥ ស្ដីពីការរៀបចំក្រុមការងារយេនឌ័រ ប្រចាំក្រសួង-ស្ថាប័នពាក់ព័ន្ធ
- យោងតាមការចាំបាច់

# ស ម្រេ ច

**ប្រការ១** : បង្កើតក្រុមការងារយេនឌ័រនៅក្នុងក្រសួងផែនការ ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **អ៊ូ ឱហាត** | រដ្ឋលេខាធិការ ក្រសួងផែនការ | ប្រធាន |
| ២. | ឯកឧត្តម **នូត ចំនួសុខា** | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធាន |
| ៣. | លោកជំទាវ **ហង់ លីណា** | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. | ឯកឧត្តម **ថេង បញ្ញាធន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ | អនុប្រធាន |
| ៥. | លោកស្រី **ជួង សារុន** | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន | អនុប្រធាន |
| ៦. | លោក **ម៉ូច សុវណ្ណឌី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ | សមាជិក |
| ៧. | លោក **ខាវ ចាន់ឆុំ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ | សមាជិក |
| ៨. | លោក **ទ៉ាវ សុផល** | អគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ | សមាជិក |
| ៩. | លោក **ហួយ សុន្ធិគុណ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ | សមាជិក |
| ១០. | លោកជំទាវ **ខុន នារី** | អធិការ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ១១. | លោក **ចី យារម** | ប្រធាននាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេត | សមាជិក |
| ១២. | លោក **ណុប គនណរាទុឡ្យ** | ប្រធាននាយកដ្ឋានផែនការវិនិយោគ នៃអគ្គនាយកដ្ឋានផែនការ | សមាជិក |
| ១៣. | កញ្ញា **តុង សែរីន** | ទីប្រឹក្សាអមក្រសួងផែនការ | សមាជិក |
| ១៤. | លោក **យឹង ជឹម** | ជំនួយការក្រសួងផែនការ | សមាជិក |
| ១៥. | លោកស្រី **ឈុន នទី** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ១៦. | កញ្ញា **មាស រ័ត្នមណី** | អនុប្រធាននាយកដ្ឋានស្ថិតសេដ្ឋកិច្ច | សមាជិក |
| ១៧. | លោកស្រី **ហេង ទិចិត្រ** | អនុប្រធាននាយកដ្ឋានស្តង់ដារ និងវិភាគស្ថិតិ | សមាជិក |
| ១៨. | កញ្ញា **លី រស្មី** | ប្រធានការិយាល័យទូរភាគី នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ | សមាជិក |
| ១៩. | កញ្ញា **កោះ កុស្សនិត** | អនុប្រធានការិយាល័យ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ | សមាជិក |
| ២០. | កញ្ញា **ទ៉ាត នារីរតនា** | អនុប្រធានការិយាល័យ នាយកដ្ឋានប្រជាសាស្ត្រ ជំរឿន និងអង្កេត | សមាជិក |
| ២១. | លោកស្រី **ជូ ពុទ្ធានី** | ប្រធាននាយកដ្ឋានផែនការសង្គមកិច្ច នៃអគ្គនាយកដ្ឋានផែនការ | លេខាទី១ |
| ២២. | លោកស្រី **ឡុង ហួរសេទី** | អនុប្រធាននាយកដ្ឋានផែនការសង្គមកិច្ច អគ្គនាយកដ្ឋានផែនការ | លេខាទី ២ |
| ២៣. | លោក **ទ្រី ម៉េងសាង** | អនុប្រធាននាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេត | លេខាទី ៣ |

**ប្រការ២** : ក្រុមការងារយេនឌ័រនេះ មានភារកិច្ចដូចតទៅ:

- បញ្ជ្រាបទស្សនៈយេនឌ័រទៅក្នុងគ្រប់ផែនការ គោលនយោបាយ កម្មវិធី ដែលរៀបចំឡើងដោយក្រសួងផែនការ
- បណ្តុះបណ្តាលអំពីការបញ្ជ្រាបយេនឌ័រក្នុងក្រសួងផែនការ និងមន្ទីរផែនការរាជធានី-ខេត្ត

- សម្របសម្រួលវគ្គបណ្តុះបណ្តាល សិក្ខាសាលា ស្តីពីការបញ្ជ្រាបយេនឌ័រដែលទាក់ទងទៅនឹងសកម្មភាពផែនការជាក់លាក់
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលចំណេះដឹងផ្នែកយេនឌ័រក្នុងក្រសួងផែនការ ថ្នាក់កណ្តាលនិងតាមបណ្តារាជធានី ខេត្ត មូលដ្ឋាន
- ធ្វើទំនាក់ទំនង និងសហការ ជាមួយក្រុមការងារយេនឌ័រនៃក្រសួងកិច្ចការនារី ដើម្បីរៀបចំនិងអនុវត្តការងារផ្សេងៗទាក់ទងនឹងការងារយេនឌ័រ
- សម្របសម្រួល និងស្វែងរកការគាំទ្រទាំងផ្នែកថវិកានិងបច្ចេកទេស ពី ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ ដើម្បីដំណើរការការងារ និងលើកកម្ពស់ការងារយេនឌ័រក្នុងក្រសួងផែនការ
- ធ្វើរបាយការណ៍ពីស្ថានភាពយេនឌ័រ និងសកម្មភាពដែលក្រុមការងារយេនឌ័រអនុវត្ត ទាំងក្នុងនិងក្រៅក្រសួងផែនការជូនដល់ថ្នាក់ដឹកនាំក្រសួង
- តាមដានត្រួតពិនិត្យនិងវាយតម្លៃ ពីការងារអនុវត្តពាក់ព័ន្ធនឹងការងារយេនឌ័រ

**ប្រការ៣** : ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៤** : ប្រកាសទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**ចម្លងជូន** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងកិច្ចការនារី
- គ្រប់អង្គភាពពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ ២

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួង ផែនការ**

លេខ: ៣៩៥ ប្រ.ក.ផក.

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០១០

## ប្រ ក ា ស

ស្តីពី

**ការបង្កើតមន្ត្រីបង្គោលយេនឌ័រ មន្ទីរផែនការរាជធានី ខេត្ត**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២នស/១៩៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៧ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងឥស្សរជនចំនួន ២០៥រូប ជា អនុរដ្ឋលេខាធិការ នៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិកាដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញ អនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង កិច្ចការនារី
- បានឃើញ លិខិតរបស់ក្រសួងកិច្ចការនារីលេខ ៣៧៨ កកន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការរៀបចំក្រុមការងារ យេនឌ័រប្រចាំក្រសួង-ស្ថាប័នពាក់ព័ន្ធ
- យោងតាមការចាំបាច់

## ស ម្រេ ច

**ប្រការ១** : បង្កើតមន្ត្រីបង្គោលយេនឌ័រ មន្ទីរផែនការរាជធានី ខេត្ត ដែលមានឈ្មោះដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | លោកស្រី **ម៉ុំ សណ្ឋប់** | ប្រធានមន្ទីរផែនការរាជធានីភ្នំពេញ | មន្ត្រីបង្គោល |
| ២. | លោកស្រី **ឡាំ ស៊ីណា** | ប្រធានមន្ទីរផែនការខេត្តបន្ទាយមានជ័យ | មន្ត្រីបង្គោល |
| ៣. | លោក **ខេន ផល្លី** | អនុប្រធានមន្ទីរផែនការខេត្តកំពង់ឆ្នាំង | មន្ត្រីបង្គោល |
| ៤. | លោក **អ៊ិន គីមស៊ា** | អនុប្រធានមន្ទីរផែនការខេត្តក្រចេះ | មន្ត្រីបង្គោល |
| ៥. | លោក **យី រិទ្ធ** | អនុប្រធានមន្ទីរផែនការខេត្តឧត្តរមានជ័យ | មន្ត្រីបង្គោល |
| ៦. | លោក **សំ លាស់** | អនុប្រធានមន្ទីរផែនការខេត្តកំពង់ស្ពឺ | មន្ត្រីបង្គោល |
| ៧. | លោកស្រី **អន ស៊ីថុនគីរី** | អនុប្រធានមន្ទីរផែនការខេត្តស្ទឹងត្រែង | មន្ត្រីបង្គោល |
| ៨. | លោក **អ៊ឹម សុខឡេង** | ប្រធានការិយាល័យ មន្ទីរផែនការខេត្តកំពង់ធំ | មន្ត្រីបង្គោល |
| ៩. | លោកស្រី **ឈឹម ណារិន** | ប្រធានការិយាល័យ មន្ទីរផែនការខេត្តកំពត | មន្ត្រីបង្គោល |
| ១០. | លោក **ចាន់ តារា** | ប្រធានការិយាល័យ មន្ទីរផែនការខេត្តកណ្ដាល | មន្ត្រីបង្គោល |
| ១១. | លោក **ឆិត ឆៃ** | ប្រធានការិយាល័យ មន្ទីរផែនការខេត្តស្វាយរៀង | មន្ត្រីបង្គោល |
| ១២. | លោកស្រី **លឹម សាត** | ប្រធានការិយាល័យ មន្ទីរផែនការខេត្តព្រះវិហារ | មន្ត្រីបង្គោល |
| ១៣. | កញ្ញា **រ៉ាន់ គន្ធារ៉ា** | អនុប្រធានការិយាល័យ មន្ទីរផែនការខេត្តកំពង់ចាម | មន្ត្រីបង្គោល |
| ១៤. | កញ្ញា **ម៉ែន ស៊ីណាចិន្តា** | អនុប្រធានការិយាល័យ មន្ទីរផែនការខេត្តមណ្ឌលគីរី | មន្ត្រីបង្គោល |
| ១៥. | លោកស្រី **ស៊ូ រ៉ី** | អនុប្រធានការិយាល័យ មន្ទីរផែនការខេត្តព្រៃវែង | មន្ត្រីបង្គោល |
| ១៦. | លោកស្រី **សរ ពុទ្ធារី** | អនុប្រធានការិយាល័យ មន្ទីរផែនការខេត្តសៀមរាប | មន្ត្រីបង្គោល |
| ១៧. | លោកស្រី **យ៉ាន់ សុគុន** | អនុប្រធានការិយាល័យ មន្ទីរផែនការខេត្តព្រះសីហនុ | មន្ត្រីបង្គោល |
| ១៨. | លោកស្រី **គូ ទីណៃ** | អនុប្រធានការិយាល័យ មន្ទីរផែនការខេត្តប៉ៃលិន | មន្ត្រីបង្គោល |
| ១៩. | លោកស្រី **អៀម ចន្ធា** | អនុប្រធានការិយាល័យ មន្ទីរផែនការខេត្តពោធិសាត់ | មន្ត្រីបង្គោល |
| ២០. | លោកស្រី **ហួត ស៊ីណាត** | មន្ត្រី មន្ទីរផែនការខេត្តបាត់ដំបង | មន្ត្រីបង្គោល |
| ២១. | លោក **ចាន់ សុតា** | មន្ត្រី មន្ទីរផែនការខេត្តកែប | មន្ត្រីបង្គោល |
| ២២. | កញ្ញា **ជិន ស្រីនាង** | មន្ត្រី មន្ទីរផែនការខេត្តរតនៈគីរី | មន្ត្រីបង្គោល |
| ២៣. | លោកស្រី **ហ៊ីន សុខា** | មន្ត្រី មន្ទីរផែនការខេត្តតាកែវ | មន្ត្រីបង្គោល |
| ២៤. | លោកស្រី **តៅ ចន្ធី** | មន្ត្រី មន្ទីរផែនការខេត្តកោះកុង | មន្ត្រីបង្គោល |

**ប្រការ២** : មន្ត្រីបង្គោលយេនឌ័រនេះ មានភារកិច្ចដូចតទៅ:

- បញ្ជ្រាបទស្សនៈយេនឌ័រទៅក្នុងគ្រប់ផែនការ គោលនយោបាយ កម្មវិធី ដែលរៀបចំឡើងដោយក្រសួងផែនការ
- បណ្តុះបណ្តាលអំពីការបញ្ជ្រាបយេនឌ័រក្នុងមន្ទីរផែនការ រាជធានី-ខេត្ត
- សម្របសម្រួល វគ្គបណ្តុះបណ្តាល សិក្ខាសាលា ស្តីពីការបញ្ជ្រាបយេនឌ័រដែលទាក់ទងទៅនឹងសកម្មភាពផែនការជាក់លាក់
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលចំណេះដឹងផ្នែកយេនឌ័រ ក្នុងមន្ទីរផែនការរាជធានី ខេត្ត និងតាមមូលដ្ឋាន
- ធ្វើការទំនាក់ទំនង និងសហការជាមួយក្រុមការងារយេនឌ័រក្រសួងផែនការ មន្ទីរកិច្ចការនារី នៃក្រសួងកិច្ចការនារី ដើម្បី រៀបចំនិងអនុវត្ត ការងារផ្សេងៗទាក់ទងនឹងបញ្ហាយេនឌ័រ
- ផ្តល់របាយការណ៍ជាប្រចាំ ពីសកម្មភាពទាក់ទងការងារយេនឌ័រ មកក្រុមការងារយេនឌ័រក្រសួងផែនការ
- ទទួលការងារចាំបាច់មួយចំនួនទៀត ដែលទាក់ទងការងារយេនឌ័រ

**ប្រការ៣** : លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៤** : ប្រកាសទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**ចម្លងជូន** :

- ខុទ្ទការល័យឯកឧត្តមទេសរដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ក្រសួងកិច្ចការនារី
- គ្រប់អង្គភាពពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៣

## អង្គការលេខរបស់ក្រសួងផែនការ



## ឧបសម្ព័ន្ធ ៤

## អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងផែនការ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ៥៥ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងផែនការ

# រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងផែនការ

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៧

## សម្រេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ :** អនុក្រឹត្យនេះរៀបចំអង្គភាពនានារបស់ក្រសួងផែនការ និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការនៃបណ្តាអគ្គនាយកដ្ឋាន និង នាយកដ្ឋាននានា ។

## ជំពូក ២

## បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា ២ :** ក្រសួងផែនការត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់ឱ្យទទួលបន្ទុកបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យផែនការស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងលើការអនុវត្តស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣ :** ក្រសួងផែនការមានមុខងារនិងភារកិច្ចដូចតទៅ :

- ធ្វើសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ ទស្សនាទាន យុទ្ធសាស្ត្រ គោលនយោបាយ និងកំណត់អាទិភាពសម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិដោយឈរលើមូលដ្ឋាននៃការបង្កើតឱ្យមាននិរន្តរភាព និង តុល្យភាពរវាង កិច្ចអភិវឌ្ឍ និង សមភាព យុត្តិធម៌ក្នុងសង្គម រវាង កិច្ចអភិវឌ្ឍខាងសេដ្ឋកិច្ច និងកិច្ចអភិវឌ្ឍខាងសង្គមកិច្ចនិងវប្បធម៌ រវាង ទីក្រុងនិងជនបទ រវាង ការធ្វើអាជីវកម្មនិងការកកើតឡើងវិញនៃធនធានធម្មជាតិ និងរវាង កិច្ចអភិវឌ្ឍនិងការការពារបរិស្ថាន ។
- ដឹកនាំនិងគ្រប់គ្រងវិធីសាស្ត្រ និងបែបបទក្នុងការរៀបចំផែនការ ស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចតាមប្រព័ន្ធវិមជ្ឈការក្នុងក្របខ័ណ្ឌទូទាំងប្រទេស។
- រៀបចំផែនការ និងកម្មវិធីជាតិសម្រាប់កិច្ចអភិវឌ្ឍរយៈពេលវែង មធ្យម និងរយៈពេលខ្លី ដោយសម្របសម្រួល ជាមួយបណ្តាក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ដើម្បីឱ្យផែនការនិងកម្មវិធីជាតិទាំងនោះស៊ីសង្វាក់គ្នា

រវាងបណ្ដាផ្នែកនិងសាខាសេដ្ឋកិច្ច-សង្គមកិច្ច ព្រមទាំងខេត្ត-ក្រុង និងតំបន់នានាក្នុងក្របខ័ណ្ឌ ទូទាំងប្រទេស ។

- តាមដានត្រួតពិនិត្យ ការអនុវត្ត ផែនការ កម្មវិធីជាតិ និងបណ្ដាគម្រោង ពីគ្រប់ផ្នែកទាំងអស់ ហើយវាយតំលៃលទ្ធផលនៃការអនុវត្ត និងលើកឡើងពីវិធានការកែតម្រូវផែនការ កម្មវិធីជាតិទាំងនោះ ក្នុងករណីចាំបាច់ ។
- រួមជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំ យុទ្ធសាស្ត្រ គោលនយោបាយ និងកំណត់អាទិភាពក្នុងការវិនិយោគទាំងឯកជន និងសាធារណៈ ដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពនូវសក្ដានុពលនៃប្រភពធនធាន ទាំងក្នុង និងក្រៅប្រទេស ។
- សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីកំណត់និងបែងចែកទុនវិនិយោគសាធារណៈប្រចាំឆ្នាំ ។
- រួមជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំ យុទ្ធសាស្ត្រ គោលនយោបាយ និងកំណត់អាទិភាពក្នុងផែនការសហប្រតិបត្តិការសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌និងវិទ្យាសាស្ត្របច្ចេកទេស ជាមួយបរទេស ឱ្យស៊ីសង្វាក់គ្នាជាមួយនឹងទិសដៅនិងគោលនយោបាយអភិវឌ្ឍន៍ជាតិ ។
- រួមជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំគោលនយោបាយប្រជាសាស្ត្រ និងផែនការសកម្មភាពស្ដីពី ការបែងចែកកំលាំងពលកម្មសង្គមឱ្យមានតុល្យភាព ធានាដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច និងការពារជាតិ ។
- ធ្វើការអង្កេត និងការសិក្សាស្រាវជ្រាវដែលចាំបាច់ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ។
- គ្រប់គ្រងព័ត៌មានស្ថិតិសេដ្ឋកិច្ច-សង្គមកិច្ច និងប្រជាសាស្ត្រក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- គ្រប់គ្រងប្រព័ន្ធស្ថិតិជាតិកម្ពុជាតាមការចងក្រង ណែនាំអនុវត្តវិធីប្រើចំណាត់ថ្នាក់ស្ថិតិ និងគំរូតារាងឯកភាព ក្នុងការបំពេញនិងការប្រមូលយកព័ត៌មានស្ថិតិ ណែនាំអនុវត្តវិធីសាស្ត្រ និងរូបមន្តគណនាទិន្នន័យស្ថិតិឯកភាពក្នុងទូទាំងប្រទេស ។
- រៀបចំវិធីសាស្ត្រធ្វើជំរឿន ធ្វើអង្កេត និងអនុវត្តការធ្វើជំរឿន ការធ្វើអង្កេតប្រជារាស្ត្រសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ។
- ផ្ដល់ជំនួយខាងផ្នែកបច្ចេកទេសនិងវិធីសាស្ត្រ ឬអនុវត្តការធ្វើជំរឿននិងអង្កេតក្នុងវិស័យ និងប្រធានបទនានាតាមសំណូមពររបស់អ្នកប្រើប្រាស់ទិន្នន័យស្ថិតិ ។
- ចងក្រងគណនេយ្យជាតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវាកម្ម និងកម្រងតួលេខស្ថិតិរបស់កម្ពុជាទៀងទាត់ជាប្រចាំ ។
- សហការដោះដូរព័ត៌មានជាមួយអង្គភាពស្ថិតិជាតិនៃប្រទេសក្នុងតំបន់ក្នុងពិភពលោក និងបណ្ដាអង្គការជាតិ អង្គការអន្តរជាតិ ។
- បំពេញមុខងារនិងភារកិច្ចចាំបាច់ផ្សេងទៀតតាមការទុកចិត្តនិងការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ។

**មាត្រា ៤ :** ក្រសួងផែនការមានរចនាសម្ព័ន្ធដូចតទៅ :

**ក. នៅថ្នាក់កណ្តាល**

- អគ្គនាយកដ្ឋានផែនការរួមមាន :
  - ➢ នាយកដ្ឋានផែនការទូទៅ
  - ➢ នាយកដ្ឋានផែនការសេដ្ឋកិច្ច
  - ➢ នាយកដ្ឋានផែនការសង្គមកិច្ច
  - ➢ នាយកដ្ឋានផែនការវិនិយោគ
  - ➢ នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ
- វិទ្យាស្ថានជាតិស្ថិតិដែលមានឋានានុក្រមស្មើថ្នាក់អគ្គនាយកដ្ឋានរួមមាន:
  - ➢ នាយកដ្ឋានស្ថិតិទូទៅ
  - ➢ នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច
  - ➢ នាយកដ្ឋានស្ថិតិសង្គមកិច្ច
  - ➢ នាយកដ្ឋានប្រជាសាស្ត្រ ជំរឿន និងអង្កេត
- អគ្គាធិការដ្ឋាន
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានរដ្ឋបាលទូទៅ
- នាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញវត្ថុ

**ខ. អង្គភាពមូលដ្ឋាន**

- មន្ទីរផែនការខេត្ត ក្រុង

អង្គការលេខរបស់ក្រសួងផែនការ មានភ្ជាប់ក្នុងឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូក ៣

## អគ្គនាយកដ្ឋានផែនការ

**មាត្រា ៥ :** អគ្គនាយកដ្ឋានផែនការមានមុខងារអនុវត្តនូវរាល់បេសកកម្មរបស់ក្រសួងក្នុងការ :

- ធានាភាពស៊ីសង្វាក់គ្នាក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ដោយសម្របសម្រួលផែនការ កម្មវិធីនិងគម្រោងអភិវឌ្ឍន៍តាមផ្នែកនិងសាខាសេដ្ឋកិច្ច ដែលរៀបចំឡើងដោយបណ្តាក្រសួង-រដ្ឋលេខាធិការដ្ឋាន ស្ថាប័នដែលពាក់ព័ន្ធ និងខេត្ត-ក្រុង ។

- តាមដានត្រួតពិនិត្យការអនុវត្តផែនការ និងកម្មវិធីជាតិ ដោយសហការជាមួយក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នដែលពាក់ព័ន្ធ និងខេត្ត-ក្រុង ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនរដ្ឋមន្ត្រី ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ សម្រេច ។
- រៀបចំរបាយការណ៍ស្តីពីសភាពការណ៍សេដ្ឋកិច្ច-សង្គមកិច្ច ប្រចាំត្រីមាសទី១ ឆមាសទី១ ៩ខែដើមឆ្នាំ និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដោយសម្របសម្រួលជាមួយក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នដែលពាក់ព័ន្ធ ខេត្ត ក្រុង និងវិទ្យាស្ថានជាតិស្ថិតិ ។

អគ្គនាយកដ្ឋានផែនការត្រូវដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានផែនការមាននាយកដ្ឋានចំណុះចំនួន ៥ ដូចខាងក្រោម ហើយនាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

**មាត្រា ៦ : នាយកដ្ឋានផែនការទូទៅ** ទទួលបន្ទុក :

- កសាងទស្សនទាន យុទ្ធសាស្ត្រផែនការនិងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចជាតិរយៈពេលខ្លី មធ្យម និងរយៈពេលវែង ដោយសម្របសម្រួលជាមួយនាយកដ្ឋាននានាចំណុះអគ្គនាយកដ្ឋានផែនការ
- វិភាគនិងព្យាករណ៍ពីស្ថានភាពរួមនៃការវិវត្ត ខាងផ្នែកម៉ាក្រូសេដ្ឋកិច្ចនៅក្នុងប្រទេស ព្រមទាំងលើកឡើង នូវយោបល់និងវិធានការចាំបាច់ ដើម្បីកែតម្រង់ទិសដៅនៃការអភិវឌ្ឍប្រទេស ឱ្យបានទាន់ពេលវេលា ។
- រៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ចរួមមានគណនេយ្យជាតិ សារពើពន្ធ ជញ្ជីងទូទាត់ រូបិយវត្ថុ និងស្ថាប័នហិរញ្ញវត្ថុ ។

**មាត្រា ៧ : នាយកដ្ឋានផែនការសេដ្ឋកិច្ច** ទទួលបន្ទុក :

- វិភាគនិងព្យាករណ៍អំពីស្ថានភាពរួម នៃការវិវត្តខាងផ្នែកសេដ្ឋកិច្ចនានានៅក្នុងប្រទេស ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ដើម្បីកែតម្រង់ទិដៅនៃការអភិវឌ្ឍប្រទេស ឱ្យបានទាន់ពេលវេលា។
- រៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការក្នុងវិស័យសេដ្ឋកិច្ចនានារួមមានជាអាទិ៍ កសិកម្ម រុក្ខាកម្ម នេសាទ ឧស្សាហកម្ម គមនាគមន៍ ដឹកជញ្ជូន ពាណិជ្ជកម្ម ទេសចរណ៍ សំណង់ និងបរិស្ថាន ។

**មាត្រា ៨ : នាយកដ្ឋានផែនការសង្គមកិច្ច** ទទួលបន្ទុក :

- វិភាគនិងព្យាកណ៍អំពីស្ថានភាពរួមនៃការវិវត្តខាងផ្នែកសង្គមកិច្ចនិងស្ថានភាពប្រជាសាស្ត្រ នៅក្នុងប្រទេស ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ដើម្បីកែតម្រង់ទិសដៅនៃការអភិវឌ្ឍ ឱ្យបានទាន់ពេលវេលា ។

- រៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការក្នុងវិស័យសង្គមកិច្ចរួមមាន ការងារប្រជាសាស្ត្រ អប់រំបណ្តុះបណ្តាល អភិវឌ្ឍន៍ធនធានមនុស្ស អភិវឌ្ឍន៍សហគមន៍ ការកាត់បន្ថយភាពក្រីក្រ ផ្ទះសំបែង សុខាភិបាល អាហារូបត្ថម្ភ សង្គមកិច្ច-ការងារ វប្បធម៌ តួនាទីបុរសស្ត្រី សាសនា និងព័ត៌មាន ។

**មាត្រា ៩ នាយកដ្ឋានផែនការវិនិយោគ** ទទួលបន្ទុក :

- វិភាគនិងព្យាករណ៍អំពី ស្ថានភាពរួមនៃការវិវត្ត ខាងផ្នែកវិនិយោគនៅក្នុងប្រទេស ទាំងវិនិយោគសាធារណៈ និងឯកជន ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ ដើម្បីតម្រង់ទិសវិនិយោគឱ្យសមស្របតាមទិសដៅនៃការអភិវឌ្ឍប្រទេស ។
- រៀបចំយុទ្ធសាស្ត្រវិនិយោគរយៈពេលខ្លី មធ្យម និងវែង ។
- កំណត់អាទិភាពក្នុងការបែងចែកទុនតាមវិស័យ ។
- ពិនិត្យសេចក្តីព្រាងគម្រោងវិនិយោគសាធារណៈរបស់បណ្តាក្រសួងនិងស្ថាប័ននានា ។
- រៀបចំកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ ។
- ចូលរួមក្នុងគណៈកម្មការដេញថ្លៃលើគ្រប់គម្រោងការងារវិនិយោគសាធារណៈ ។
- តាមដាននិងវាយតំលៃលទ្ធផលនៃការអនុវត្តន៍កម្មវិធីវិនិយោគសាធារណៈ ។

**មាត្រា ១០ : នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ** ទទួលបន្ទុក :

- វិភាគនិងព្យាករណ៍ពីស្ថានភាពរួមនៃការងារសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយបរទេស អង្គការអន្តរ-ជាតិ និងអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ ដើម្បីតម្រង់ទិសការងារសហប្រតិបត្តិការសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌និងវិទ្យាសាស្ត្របច្ចេកទេស ជាមួយបរទេសឱ្យស្របតាមទិសដៅនៃការអភិវឌ្ឍន៍ប្រទេស ។
- ធ្វើសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មាន និងសម្របសម្រួលក្នុងក្រមខ័ណ្ឌការងារផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចជាមួយបរទេសតាមការចាំបាច់ ។
- សម្របសម្រួលការងារសហប្រតិបត្តិការសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌និងវិទ្យាសាស្ត្របច្ចេកទេសជាមួយបរទេសផ្សេងទៀតតាមការចាំបាច់ និងតាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល ជាអាទិ៍ដូចជា ការងារក្នុងក្របខ័ណ្ឌ នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងបណ្តាប្រទេសក្នុងអនុតំបន់ទន្លេមេគង្គ ជាដើម ។

# ជំពូក ៤
# វិទ្យាស្ថានជាតិស្ថិតិ

**មាត្រា ១១ : វិទ្យាស្ថានជាតិស្ថិតិ** មានមុខងារ :

- អនុវត្តរាល់បេសកកម្មរបស់ក្រសួងក្នុងការធ្វើជំរឿន អង្កេតអំពី សេដ្ឋកិច្ច-សង្គមកិច្ច និងប្រជាសាស្ត្រ ។ ចងក្រងនិងណែនាំវិធីប្រើប្រាស់ចំណាត់ថ្នាក់ស្ថិតិ តារាងឯកភាព និងវិធីសាស្ត្រគណនាទិន្នន័យស្ថិតិ ប្រមែប្រមូល ចងក្រងនិងផ្សព្វផ្សាយទិន្នន័យស្ថិតិស្តីពី ស្ថានភាពនៃការវិវត្តក្នុងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច នៅក្នុងប្រទេស ។
- សហការជាមួយអង្គភាពស្ថិតិជាតិនៃប្រទេសនានាក្នុងតំបន់ និងពិភពលោក ក្នុងការដោះដូរព័ត៌មានស្ថិតិ បណ្តុះបណ្តាលមន្ត្រីជំនាញការងារស្ថិតិដើម្បីការអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិកម្ពុជា ។ វិទ្យាស្ថានជាតិស្ថិតិ ត្រូវដឹកនាំដោយអគ្គនាយកមួយរូប ដែលតែងតាំងដោយព្រះរាជក្រឹត្យ និងនាយករងមួយចំនួន ជួយធ្វើការ តាមការចាំបាច់ ។
- វិទ្យាស្ថានជាតិស្ថិតិមាននាយកដ្ឋានចំណុះចំនួន ៤ ដូចខាងក្រោម ហើយនាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជួយធ្វើការ តាមការចាំបាច់ ។

**មាត្រា ១២ : នាយកដ្ឋានស្ថិតិទូទៅ** ទទួលបន្ទុក :

- សម្របសម្រួលទិន្នន័យស្ថិតិជាមួយនាយកដ្ឋាននានាចំណុះវិទ្យាស្ថានជាតិស្ថិតិ ដើម្បីចងក្រងចេញនូវគណនេយ្យជាតិរបស់កម្ពុជា ។
- ប្រមូលយកព័ត៌មានអំពីថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម តាមកាលកំណត់ និងចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មប្រចាំ ខែ ត្រីមាស ឆមាស ៩ខែដើមឆ្នាំ និងប្រចាំឆ្នាំ របស់កម្ពុជា ។
- ចងក្រង ផ្សព្វផ្សាយ និងណែនាំអនុវត្តដោយឯកភាពនូវចំណាត់ថ្នាក់ ព័ត៌មានស្ថិតិ បណ្តាតារាងគំរូប្រមូលយកព័ត៌មានស្ថិតិពីអង្គភាពរដ្ឋ ឯកជន គ្រឹះស្ថានសាធារណៈនានាសម្រាប់ ចងក្រងទិន្នន័យស្ថិតិជាតិ ។

**មាត្រា ១៣ : នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច** ទទួលបន្ទុក :

- ប្រមូល ចងក្រង ព័ត៌មានបឋមស្តីពី ស្ថិតិ កសិកម្ម រុក្ខាកម្ម នេសាទ ឧស្សាហកម្ម ពាណិជ្ជកម្ម សំណង់ គមនាគមន៍ ដឹកជញ្ជូន ទេសចរណ៍ និងស្ថិតិបរិស្ថាន ។
- សិក្សា និងសហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំនិងធ្វើជំរឿន អង្កេត ប្រមូលចងក្រង និងវិភាគព័ត៌មាន ស្ថិតិកសិកម្ម រុក្ខាកម្ម នេសាទ ឧស្សាហកម្ម ពាណិជ្ជកម្ម សំណង់ គមនាគមន៍ ដឹកជញ្ជូន ទេសចរណ៍ និងស្ថិតិបរិស្ថាន ។

**មាត្រា ១៤ : នាយកដ្ឋានស្ថិតិសង្គមកិច្ច** ទទួលបន្ទុក :

- ប្រមូលចងក្រងព័ត៌មានបឋមស្តីពី ស្ថិតិសង្គមកិច្ច-ការងារ ស្ថិតិអប់រំសិក្សា ស្ថិតិសុខាភិបាល ស្ថិតិព័ត៌មាន និងស្ថិតិវប្បធម៌ ។
- សិក្សា និងសហការ ជាមួយអង្គភាពពាក់ព័ន្ធ រៀបចំនិងធ្វើជំរឿន អង្កេតប្រមូលចងក្រង និងវិភាគព័ត៌មាន ស្ថិតិសង្គមកិច្ច-ការងារ ស្ថិតិអប់រំសិក្សា ស្ថិតិសុខភិបាល ស្ថិតិព័ត៌មាន និងស្ថិតិវប្បធម៌ ។

**មាត្រា ១៥ : នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន អង្កេត** ទទួលបន្ទុក :

- ធ្វើជំរឿន អង្កេត ប្រមូល ចងក្រង និងគ្រប់គ្រងស្ថិតិប្រជាសាស្ត្រ ។
- សហការធ្វើការរៀបចំ អនុវត្តការធ្វើជំរឿន អង្កេតតាមប្រធានបទនានា ក្នុងសំណូមពរ របស់បណ្តាអង្គភាព និងអ្នកប្រើប្រាស់ទិន្នន័យស្ថិតិ ។
- ធ្វើការបណ្តុះបណ្តាលបំពេញសមត្ថភាពជំនាញស្ថិតិ ពីថ្នាក់កណ្តាលរហូតដល់មូលដ្ឋានតាម តម្រូវការការងារ ។

## ជំពូក ៥

## អគ្គាធិការដ្ឋាន

**មាត្រា ១៦ : អគ្គាធិការដ្ឋាន** របស់ក្រសួងផែនការទទួលបន្ទុក :

- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងផែនការ ។
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយកែលម្អការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនេះ ។
- ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋមន្ត្រីបានប្រគល់ការទុកចិត្ត ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប អមដោយអគ្គាធិការរងមួយ ឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

## ជំពូក ៦

## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ១៧ :** ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

# ជំពូក ៧

# ការងាររដ្ឋបាល និង ហិរញ្ញវត្ថុ

**មាត្រា ១៨ : នាយកដ្ឋានរដ្ឋបាលទូទៅ** ទទួលបន្ទុក :

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ ។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ។
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។
- តំកល់ឯកសារ និងគ្រប់គ្រងបណ្ណាល័យ ។

**មាត្រា ១៩ : នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ** ទទួលបន្ទុក :

- ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសំភារៈ និងបរិក្ខាររបស់ក្រសួង ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ។
- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ។ ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ ។
- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពខេត្ត ក្រុងនានា ។
- កាន់បញ្ជីជាប្រចាំនូវសាលាប័ត្រ និងគណនេយ្យរូបធាតុ ។
- ព័ត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។
- លើកគម្រោងថវិកាក្រសួង និងតាមដានវំលើកពីការប្រតិបត្តិ ។
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា ។
- តាមដានវំលើកការគ្រប់គ្រងគណនីពិសេស ។
- ប្រមូលផ្តុំ និងសម្របសម្រួលវាល់ចំណាយរបស់ក្រសួង ។
- គ្រប់គ្រងបន្ទុកគណនីនៃការអនុវត្តលទ្ធកម្មសាធារណៈ ។
- ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់ ។

**មាត្រា ២០ :** នាយកដ្ឋានបុគ្គលិក ទទួលបន្ទុក :

**ក. ក្នុងវិស័យបុគ្គលិក**

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនង នឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- រៀបចំរាល់លិខិតរដ្ឋបាលសម្រាប់ការគ្រប់គ្រងអាជីព ។
- ធ្វើកម្មវិធីតំណែងឯកទេស និង ធនធានមនុស្សរបស់ក្រសួង ។
- វាយតំលៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក ។
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនងនឹរដ្ឋលេខាធិការដ្ឋានមុខ ងារសាធារណៈ និងអនុវត្តនយោបាយនោះ ។
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងព័តិមានប្រតិបត្តិ ។
- គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

**ខ. ក្នុងវិស័យបណ្តុះបណ្តាល :** មជ្ឈមណ្ឌលបណ្តុះបណ្តាលក្របខ័ណ្ឌផែនការ-ស្ថិតិ ទទួលបន្ទុក :

- រៀបចំការប្រឡងជ្រើសរើសនិងធ្វើការបណ្តុះបណ្តាលនូវមុខវិជ្ជាជំនាញចាំបាច់ក្នុងវិស័យ ផែនការនិងស្ថិតិ
- រៀបចំធ្វើវិក្រឹតការ និងសុក្រឹតការចំពោះមន្ត្រីរាជការរបស់ក្រសួង ។

## ជំពូក ៨

## អង្គភាពមូលដ្ឋាន

**មាត្រា ២១ :** នៅតាមខេត្ត ក្រុងនីមួយៗមានមន្ទីរផែនការខេត្ត ក្រុង ទទួលបន្ទុកអនុវត្ត និងសម្របសម្រួល សកម្មភាព របស់ក្រសួង ។

## ជំពូក ៩

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ២២ :** អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមលក្ខខណ្ឌ នៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័ន ត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក ១០
## អវសានបញ្ញត្តិ

**មាត្រា ២៣ :** ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្ដាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋាន ចុះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ ។

**មាត្រា ២៤ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ២៦ :** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ១៩៩៧

**នាយករដ្ឋមន្ត្រីទី១** **នាយករដ្ឋមន្ត្រីទី២**

**អ៊ឹង ហួត** **ហ៊ុន សែន**

គោរពជូន

- នាយករដ្ឋមន្ត្រីទី ១
- នាយករដ្ឋមន្ត្រីទី ២

រដ្ឋមន្ត្រីក្រសួងផែនការ

**ជា ចាន់តូ**

**ចម្លងជូន**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រីទី ២
- គ្រប់ក្រសួងស្ថាប័នកណ្ដាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ២៥
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៥

## អនុក្រឹត្យលេខ ៨៥ អនក្រ.បក ស្តីពី ការបង្កើតនាយកដ្ឋានមួយចំនួន ចំណុះវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៨៥ អនក្រ.បក.**

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតនាយកដ្ឋានមួយចំនួន**

**ចំណុះវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រេ ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ-បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងផែនការ

- បានឃើញអនុក្រឹត្យ លេខ ០៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងកិច្ចដំណើរការ របស់ប្រព័ន្ធស្ថិតិជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតនាយកដ្ឋានស្តង់ដារស្ថិតិនិងវិភាគស្ថិតិ នាយកដ្ឋានបច្ចេកវិទ្យា ទូរគមនាគមន៍ និងព័ត៌មានវិទ្យា នាយកដ្ឋានគណនេយ្យជាតិ និង នាយកដ្ឋានគោលនយោបាយនិងសម្របសម្រួលស្ថិតិ ចំណុះវិទ្យាស្ថានជាតិស្ថិតិ បំពេញបន្ថែម លើអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ ក្រសួងផែនការ ។

## ជំពូកទី ២

## អំពីរចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា ២.-**

នាយកដ្ឋាននីមួយៗដែលមានចែងក្នុងមាត្រា ១ ត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយដ្ឋានមួយរូប និង អនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ ។

នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានទាំងអស់នេះ ត្រូវកំណត់ដោយប្រកាស របស់ ក្រសួងផែនការ ។

## ជំពូកទី ៣

## ភារកិច្ច

**មាត្រា ៣.-**

នាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- រៀបចំ និងចងក្រងចំណាត់ថ្នាក់ស្ថិតិជាតិ ដើម្បីបម្រើឱ្យការផលិតទិន្នន័យជំរឿន អង្កេត និងការវិភាគ
- រៀបចំ និងចងក្រងទស្សនាទាន និយមន័យស្ថិតិជាតិ

- រៀបចំ និងចងក្រងវិធីសាស្ត្រស្ថិតិរបស់ស្ថិតិផ្លូវការតាមវិស័យ ដើម្បីធានាដំណើរការផលិត ទិន្នន័យស្ថិតិផ្លូវការ ឱ្យបានត្រឹមត្រូវ មានគុណភាព និងគួរទុកចិត្តបាន
- សម្របសម្រួលក្នុងការអនុវត្តស្តង់ដារស្ថិតិ និយមន័យស្ថិតិ និងវិធីសាស្ត្រស្ថិតិ ដើម្បីឱ្យអង្គភាពស្ថិតិដែលបានចាត់តាំង អនុវត្តឱ្យបានឯកភាពគ្នា
- វិភាគស៊ីជម្រៅ តាមប្រធានបទដែលបានពីការអង្កេត និងជំរឿន ដូចជា ភាពក្រីក្រ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ការប្រើប្រាស់ពេលវេលា អាហារូបត្ថម្ភ ពលកម្មកុមារ និងប្រធានបទចាំបាច់ផ្សេងទៀត
- ស្រាវជ្រាវ និងចងក្រងព័ត៌មានស្ថិតិសំខាន់ៗតាមសំណូមពរ និងតាមតម្រូវការរបស់អ្នកប្រើប្រាស់ អ្នករៀបចំគោលនយោបាយ និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ តំបន់ និងអន្តរជាតិ
- ផ្សព្វផ្សាយវិធីសាស្ត្រនៃការវិភាគស៊ីជម្រៅ ដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិនៃក្រសួងស្ថាប័នរាជរដ្ឋាភិបាល
- ទទួលបន្ទុកធ្វើបញ្ជីឈ្មោះទិន្នន័យស្ថិតិរដ្ឋបាល ជំរឿន និងអង្កេត ដែលមានស្រាប់ របស់ក្រសួងស្ថាប័ន រាជរដ្ឋាភិបាល
- ផ្តល់សេវាកម្មស្រាវជ្រាវ និងវិភាគស្ថិតិ តាមសំណូមពរ និងសេចក្តីត្រូវការរបស់ស្ថាប័នជាតិ តំបន់ និងអន្តរជាតិ ។

## មាត្រា ៤.-

នាយកដ្ឋានបច្ចេកវិទ្យា ទូរគមនាគមន៍ និងព័ត៌មានវិទ្យា មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ដំឡើង កែលម្អ ថែទាំ ជួសជុល ប្រព័ន្ធបណ្តាញកុំព្យូទ័រផ្ទៃក្នុង និងទំនាក់ទំនងបញ្ជូន ព្រមទាំងទទួលព័ត៌មាននិងទិន្នន័យ ពីក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ដោយធានាផ្តល់នូវសុវត្ថិភាព និងសេវាផ្សេងទៀត ដូចជា អ៊ិនធឺណេត អ៊ីម៉ែល ការរក្សា ការបែងចែកកសារ និងការបោះពុម្ពឯកសារ
- វិភាគតម្រូវការការងារគម្រោង អភិវឌ្ឍប្រព័ន្ធ និងដំឡើងកម្មវិធី ដោយរួមបញ្ចូលទាំង ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ កែតម្រូវបញ្ហា សម្អាតទិន្នន័យ បំប្លែងជាទិន្នន័យមូលដ្ឋាន ព្រមទាំងត្រួតពិនិត្យផ្ទៃកទន់ សម្រាប់ការអង្កេត និងជំរឿន
- បង្កើត រៀបចំ ថែរក្សា កែលម្អប្រព័ន្ធ គ្រប់គ្រងទិន្នន័យមូលដ្ឋាន កំណត់លេខកូដ និងអភិវឌ្ឍផ្ទៃកទន់ ដើម្បីអនុវត្តឱ្យមានការឯកភាព និងប្រសិទ្ធភាពនៃទិន្នន័យមូលដ្ឋាន
- បង្កើតរៀបចំវេបសាយ និងប្រព័ន្ធអេឡិចត្រូនិច ដើម្បីផ្សព្វឱ្យផ្សាយអំពីរបាយការណ៍ និងស្ថិតិ
- ទទួលបន្ទុករៀបចំ និងអនុវត្តគោលការណ៍ បែបបទប្រើប្រាស់ និងស្តង់ដារប្រព័ន្ធកុំព្យូទ័រ ដើម្បីធានា ឱ្យមានប្រសិទ្ធភាព និងសុវត្ថិភាព ក្នុងការប្រើប្រាស់ប្រព័ន្ធបណ្តាញកុំព្យូទ័រ និងទិន្នន័យ

- ត្រួតពិនិត្យការវាយបញ្ចូលទិន្នន័យ សម្អាតកំហុសទិន្នន័យបឋម និងធ្វើការណែនាំ ការវាយបញ្ចូលទិន្នន័យដោយកុំព្យូទ័រ
- ផ្តល់ការបណ្តុះបណ្តាលនិងផ្សព្វផ្សាយ ទិន្នន័យមូលដ្ឋាន កម្មវិធីសម្រាប់បញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យ តាមការកំណត់របស់ឯកសារណែនាំ និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទិន្នន័យមូលដ្ឋាន និងព័ត៌មានស្ថិតិ អ្នកប្រើប្រាស់ អ្នកអភិវឌ្ឍផ្នែកទន់ អ្នកប្រើប្រាស់ស្ថិតិនៃក្រសួង ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា និងសាធារណជន
- ស្រាវជ្រាវ និងដាក់ឱ្យប្រើប្រាស់ បច្ចេកវិទ្យាកុំព្យូទ័រថ្មីៗ ក្នុងក្រសួង ដែលទាក់ទងនឹង ការគ្រប់គ្រងប្រព័ន្ធបណ្តាញកុំព្យូទ័រ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ការវិភាគ និងគ្រោង ការវាយបញ្ចូល និងផ្ទៀងផ្ទាត់ ទិន្នន័យ អ៊ិនធឺណែត អ៊ីម៉ែល វេបសាយ ។

**មាត្រា ៥.-**

នាយកដ្ឋានគណនេយ្យជាតិ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ប៉ាន់ស្មាន និងវិភាគស្ថិតិម៉ាក្រូសេដ្ឋកិច្ច ក្រោមការគ្រប់គ្រងនៃវិទ្យាស្ថានជាតិស្ថិតិ
- ធ្វើរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ចជាតិ ការវិវត្តតាមវិស័យ អតិផរណា និងសន្ទស្សន៍ថ្លៃផ្សេងទៀត
- ចងក្រង វិភាគ និងបោះផ្សាយស្ថិតិគណនេយ្យជាតិ គណនីស្ថាប័ន គណនីលំហូរ គណនីចំណាយ គណនីមូលធន គណនីហិរញ្ញវត្ថុ គណនីពាណិជ្ជកម្មអន្តរជាតិ តារាងផ្គត់ផ្គង់និងតារាងតម្រូវការ តារាងលំហូរគណនីចូល និងលំហូរគណនីចេញ តាមប្រព័ន្ធគណនេយ្យជាតិ តាមថ្លៃថេរ និងថ្លៃបច្ចុប្បន្ន ប្រចាំឆ្នាំ
- ចងក្រង វិភាគ និងបោះពុម្ពផ្សាយ ស្ថិតិគណនេយ្យជាតិ តាមវិស័យផលិតកម្ម និងចំណាយតាមថ្លៃថេរ និងថ្លៃបច្ចុប្បន្ន ប្រចាំត្រីមាស
- អង្កេត ចងក្រង វិភាគ និងបោះពុម្ពផ្សាយ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំត្រីមាស សន្ទស្សន៍ថ្លៃនាំចេញ នាំចូល ប្រចាំត្រីមាស សន្ទស្សន៍ថ្លៃកសិកម្មប្រចាំត្រីមាស និងសន្ទសសន៍ថ្លៃផ្សេងទៀត
- ប្រមូល និងចងក្រង ទិន្នន័យរដ្ឋបាល តាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដើម្បីគាំទ្រការប៉ាន់ស្មានទិន្នផលស្ថិតិតាមវិស័យ និងគណនេយ្យជាតិប្រចាំត្រីមាស និងប្រចាំឆ្នាំ
- អង្កេត និងចងក្រង សូចនាករសេដ្ឋកិច្ចមួយចំនួន ដើម្បីធានាគុណភាពនៃការប៉ាន់ស្មានស្ថិតិគណនេយ្យជាតិ
- រៀបចំ និងធ្វើឱ្យប្រសើរឡើងនូវ វិធីសាស្ត្រប៉ាន់ស្មានគណនី និងអនុវត្តពេញលេញ តាមប្រព័ន្ធគណនេយ្យជាតិ នៃអង្គការសហប្រជាជាតិ
- រៀបចំ និងចងក្រង សៀវភៅណែនាំស្តីពី ប្រព័ន្ធគណនេយ្យជាតិ និងស្ថិតិថ្លៃ ។

**មាត្រា ៦.-**

នាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- រៀបចំគោលនយោបាយ ក្នុងការពង្រឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ ដែលបានចាត់តាំង
- រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រឹងប្រព័ន្ធស្ថិតិជាតិ និងកិច្ចសហប្រតិបត្តិការស្ថិតិ
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ដល់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គភាពឯកជន និងសាធារណៈជន ឱ្យបានដឹងអំពីសារៈសំខាន់នៃស្ថិតិ
- រកដំណោះស្រាយក្នុងករណីមានបទល្មើសស្ថិតិជាតិ
- សហប្រតិបត្តិការស្ថិតិទ្វេភាគី ពហុភាគីក្នុងតំបន់ លើពិភពលោក និងសម្របសម្រួលការងារសម្រាប់អ្នកស្រាវជ្រាវស្ថិតិអន្តរជាតិ
- សហការជាមួយស្ថាប័នជាតិ តំបន់ និងអន្តរជាតិដើម្បីផ្តល់ទិន្នន័យ និងសេវាកម្មស្ថិតិ
- គ្រប់គ្រងធនធានមនុស្ស និងបណ្តុះបណ្តាលជំនាញស្ថិតិ ដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីស្ថិតិក្រសួង ស្ថាប័នរាជរដ្ឋាភិបាល
- បូកសរុបសកម្មភាពការងារ និងធ្វើរបាយការណ៍តាមកាលកំណត់ស្តីពីការអនុវត្តការងារស្ថិតិ របស់វិទ្យាស្ថានជាតិស្ថិតិ
- គ្រប់គ្រងលិខិតស្នាម និងតម្កល់ឯកសារ
- រៀបចំ និងគ្រប់គ្រងការងារចុះធ្វើសម្ភាសន៍ និងប្រមូលទិន្នន័យស្ថិតិ
- រៀបចំផែនការយុទ្ធសាស្ត្រសកម្មភាពការងារស្ថិតិរយៈពេលខ្លី មធ្យម និងវែង
- ធ្វើគម្រោងថវិកាសម្រាប់ដំណើរការការងារស្ថិតិប្រចាំឆ្នាំ រយៈពេលខ្លី មធ្យម និងវែង របស់វិទ្យាស្ថានជាតិស្ថិតិ
- ធ្វើជាលេខាធិការដ្ឋានជូនគណៈកម្មាធិការសម្របសម្រួល ។

## ជំពូកទី ៤

## អវសានបទប្បញ្ញត្តិ

**មាត្រា ៧.-**

មាត្រា ១២ ស្តីពីនាយកដ្ឋានស្ថិតិទូទៅនៃអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកស្តីទីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីសូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**ទីកន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៦

## បញ្ជីរាយឈ្មោះ អ្នកចូលរួមរៀបចំ
## ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្រសួងផែនការ (ផយបយផក) បច្ចុប្បន្នកម្ម
## ២០០៩-២០១៣

| ល.រ | ឈ្មោះ | ភេទ | តួនាទី | ផ្សេងៗ |
|---|---|---|---|---|
| ១ | ហង់ លីណា | ស្រី | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ | |
| ២ | ថេង បញ្ញោធន | ប្រុស | អគ្គនាយករង ផែនការ | |
| ៣ | ឌួង សារុន | ស្រី | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន | |
| ៤ | ប៉ូច សុវណ្ណឌី | ប្រុស | អគ្គនាយករង ផែនការ | |
| ៥ | ជា ចាន់ទុំ | ប្រុស | អគ្គនាយករង ផែនការ | |
| ៦ | វ៉ា សុផល | ប្រុស | អគ្គនាយករង ផែនការ | |
| ៧ | ជូ ពុទ្ធានី | ស្រី | ប្រធាននាយកដ្ឋាន ផែនការសង្គមកិច្ច<br>អគ្គនាយកដ្ឋានផែនការ | |
| ៨ | ធី ឃាម | ប្រុស | ប្រធាននាយកដ្ឋាន ស្ថិតិ ប្រជាសាស្ត្រ ជំរឿន និងអង្កេត | |
| ៩ | ណុប កនណាវុឌ្ឍ | ប្រុស | ប្រធាននាយកដ្ឋានផែនការវិនិយោគ<br>អគ្គនាយកដ្ឋានផែនការ | |
| ១០ | ខុន នារី | ស្រី | អធិការ នៃអគ្គាធិការដ្ឋាន | |
| ១១ | ឡុង ហ៊ូរសេរី | ស្រី | អនុប្រធាននាយកដ្ឋានផែនការសង្គមកិច្ច<br>អគ្គនាយកដ្ឋានផែនការ | |
| ១២ | ឈុន ឆវី | ស្រី | អនុប្រធាននាយកដ្ឋានបុគ្គលិក | |
| ១៣ | យឹង ជីម | ប្រុស | ជំនួយការក្រសួងផែនការ | |
| ១៤ | ហេង វិចិត្រ | ស្រី | អនុប្រធាននាយកដ្ឋាន ស្តង់ដារ និង វិភាគស្ថិតិ | |
| ១៥ | ទ្រី ម៉េងស៊ាង | ប្រុស | អនុប្រធាននាយកដ្ឋាន ស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេត | |
| ១៦ | វ៉ាត នារីរតនា | ស្រី | អនុប្រធានការិយាល័ត នាយកដ្ឋាន ស្ថិតិ ប្រជាសាស្ត្រ<br>ជំរឿន និង អង្កេត | |
| ១៧ | សុខ វណ្ណា | ប្រុស | នាយកគម្រោងអភិវឌ្ឍន៍ប្រជាជន UNFPA | |
| ១៨ | ចាប រតនា | ប្រុស | មន្ត្រីសម្របសម្រួល UNFPA ប្រចាំក្រសួងផែនការ | |

# ឧបសម្ព័ន្ធ ៧

## ពាក្យបំព្រួញ

| | | |
|---|---|---|
| គអសក | : | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| ផយអជ | : | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ផយបយផក | : | ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្រសួងផែនការ |
| ស៊ី-ដ | : | អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់រើស អើងប្រឆាំងនឹងនារីភេទ |

**KINGDOM OF CAMBODIA**
**Nation Religion King**

**MINISTRY OF PLANNING**

# MINISTRY OF PLANNING GENDER MAINSTRAINING STRATEGIC PLAN (MOPGMSP) UPDATE, 2009-2013

**DECEMBER 2010**

**Supported by:**

UNFPA

KINGDOM OF CAMBODIA
Nation Religion King

MINISTRY OF PLANNING

# MINISTRY OF PLANNING GENDER MAINSTRAINING STRATEGIC PLAN (MOPGMSP) UPDATE, 2009-2013

DECEMBER 2010

Supported by:

UNFPA

# FOREWORD

It is a great pleasure to present the *Ministry of Planning Gender Mainstreaming Strategic Plan (MOPGMSP) Update, 2009-2013* for the Ministry of Planning. This document is the output of the Ministry of Planning's effort to implement priority strategies and actions as highlighted in the National Strategic Plan Update, 2009-2013 (para. 556) and in the Ministry of Planning Strategic Plan Update, 2009-2013 (target 18). This document is an important tool to promote gender in the planning system and national statistics. Cambodia, like other countries in the region, is working towards poverty reduction and addressing human development issues, in particular, gender equality and women's rights in all aspects of development.

The Socio-Economic Development Plans (SEDPs), the National Poverty Reduction Strategy (NPRS) 2003-2005, the Cambodia Millennium Development Goals (CMDGs) 2003-2015, the National Population Policy (NPP), the Rectangular Strategy Phase I and II, the National Strategic Development Plan (NSDP) 2006-2010, and the NSDP Update 2009-2013, all address this issue and provide strategies how to enhance gender equality and reduce gender gaps. Formulation and implementation the *MOPGMSP Update, 2009-2013* is an NSDP Update 2009-2013 target. To achieve its commitments, the Ministry of Planning has worked close with the Ministry of Women's Affairs and in broad consultation with stakeholders for formulating *MOPGMSP Update, 2009-2013.*

The *MOPGMSP Update, 2009-2013* is a very important framework for all stakeholders involved in the planning system. It does not only reflect the acknowledgement of the necessity to make positive socio-economic and political changes for women, but it also provides the direction and the content for how gender equality is to be achieved in the whole planning system.

Therefore, I would like to acknowledge the assistance from UNFPA both of technical and financial to the Ministry of Planning, especially the Ministry of Planning Gender Working Group for formulating *and implementing the MOPGMSP Update, 2009-2013.* I also would like to acknowledge the technical assistance of our consultant Dr. Kyoko Kusakabe, who has advised us in the preparation of the document.

Finally, I would like to thank the Ministry of Planning Gender Working Group, leads by H.E. Ou Orhat for his guidance in making sure that this document reflects the various concerns of Gender issues in the Ministry of Planning as well as in the Cambodian society, and dedicate this effort to our predecessors, and patriotic heroes and heroines of all times who devoted and sacrificed themselves to raise the value of the Khmer women, as well as maintain the Khmer nation for their next generations.

Phnom Penh, 07. December, 2010

CHHAY Than
Senior Minister, Minister of Planning

# TABLE OF CONTENTS


Foreword ..... i

Table of Contents ..... ii

